# សិក្សាពីតថភាពសង្គម
# តាមរយៈ
# រឿងកុលាបប៉ៃលិន និងផ្កាស្រពោន

ជាដំបូងមុននឹងធ្វើការសិក្សាឱ្យបានស៊ីជម្រៅទៅលើ តថភាពសង្គមតាមរយៈស្នាដៃអក្សរសិល្ប៍ខ្មែរ រឿងកុលាបប៉ៃលិន របស់អ្នកនិពន្ធ ញ៉ុក ថែម និងរឿងផ្កាស្រពោន របស់អ្នកនិពន្ធ នូ ហាច យើងខ្ញុំសូមធ្វើការបង្ហាញនូវចំណុចចាប់ផ្ដើមខ្លះៗ ទាក់ទងនឹងលក្ខខ័ណ្ឌការសិក្សាទៅលើប្រធានបទនេះ ដែលជាសូចនាករ ក្នុងការជម្រុញការឱ្យការសិក្សាស្រាវជ្រាវដ៏ស្ដួចស្ដើងមួយនេះ មានលក្ខណៈគ្រប់គ្រាន់ក្នុងបង្ហាញជូនអស់លោកគណៈកម្មការ និងមិត្តអ្នកអានស្នាដៃមួយនេះ បានយល់អំពីហេតុផលតាមសមគួរ ទៅលើលទ្ធផលនៃការសិក្សាខាងក្រោមនេះ។ ចំណុចទាំងនោះ រួមមានដូចជា៖

**១.ទ្រឹស្ដីទូទៅស្ដីពីតថនិយមៈ**

នៅក្នុងសិល្បៈនិង អក្សរសិល្ប៍ តថនិយម គឺជាបញ្ញត្តិមួយដែលបង្ហាញឲ្យឃើញនូវទង្វើរបស់មនុស្សនិងសង្គមដែលនៅជុំវិញ ឬក៏ជាតំណាងរូបភាពខាងក្រៅ និងវត្ថុផ្សេងៗដែលកើតឡើងចំពោះជីវិត។ ឯវត្ថុបំណងនៃចលនាតថនិយមវិញ តែងតែបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងដំណាក់កាលមួយនៃប្រវត្តិសាស្ត្រ ក្នុងគ្រប់ទម្រង់រូបភាពសិល្បៈទាំងអស់ ហើយវាត្រូវបានលេចចេញជារូបរាងពិតប្រាកដនៅក្នុងពាក់កណ្ដាលនៃសតវត្សរ៍ទី ១៩ ក្នុងប្រតិកម្មតបតទៅនឹងចលនាអណ្ដែតអណ្ដូងនិយមដែលកំពុងតែមានសភាពខ្លាំងក្លានោះ ឯការកត់សម្គាល់វិញបានបង្ហាញឲ្យឃើញថា ចលនាតថនិយម គឺមានជាប់ទាក់ទងដោយផ្ទាល់ទៅនឹងអ្វី ដែលមានជាប់ពាក់ព័ន្ធនឹងឥន្ទ្រីយារម្មណ៍[១] ទាំងឡាយ។ ឯធម្មជាតិនិយមវិញ គឺជាចលនាមួយក៏បានបង្ហាញ តាមរយៈការរៀបរាប់នៅក្នុងអក្សរសិល្ប៍ ហើយឆ្លុះបញ្ចាំងឱ្យឃើញនូវទ្រឹស្ដីវិទ្យាសាស្ត្រចំពោះសិល្បៈ ។

**២. តថនិយមនៅក្នុងអក្សរសិល្ប៍ៈ**

បើនិយាយពី លក្ខណៈតថសង្គមក្នុងអក្សរសិល្ប៍នេះ មានការឱ្យជាទ្រឹស្ដីដោយឡែកៗពីគ្នាទៅតាមការយល់ឃើញ ប្រកបដោយអំណះអំណាងរបស់ប្រាជ្ញាខាងអក្សរសិល្ប៍ និងអ្នកនិពន្ធម្នាក់ៗ។ នៅក្នុងអក្សរសិល្ប៍ចលនាតថនិយម បានកើតឡើងជាដំបូងតាមរយៈលិខិតមួយរបស់ ហ្វ្រីឌ្រីចឆាលឡឺ (Friedrich Schiller) ទៅកាន់ហ្គើត(Goethe) (នៅថ្ងៃទី២៧ ខែ មេសា ឆ្នាំ១៧៨៩) ដែលបានបរិយាយថា៖ " តថនិយមមិនអាចបង្កើតជារូបកវីម្នាក់បានទេ[២] ហើយនៅក្នុងឆ្នាំដដែលនោះ ហ្វ្រីឌ្រីចឈ្លីហ្គែល (Friedrich Schlegel) បានព្យាយាមស្វែងរកអំណះអំណាងតាមលក្ខណៈគំនិតផ្ទុយគ្នា(Paradox) ដោយពោលថា " គ្រប់ទស្សនៈវិជ្ជាទាំងអស់ គឺជាឧត្ដមគតិនិយម ហើយវាគ្មានតថនិយមដែលជាការពិតណាមួយនោះឡើយ " ។ ព្រមជាមួយស្នាដៃរបស់អ្នកនិពន្ធប្លាតូ (Plato) "សង្គ្រាមប៉ាកាប្រឆាំងនឹងកំណាព្យ ដែលមានចលនាតថនិយម "។ ចលនាមួយនេះ ត្រូវបានគេឃើញជាញឹកញាប់

---

[១] អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ក្រសួងអប់រំ យុវជននិងកីឡា បោះពុម្ពផ្សាយ២០១១ ទំព័រ២-៧
(ឥន្ទ្រីយ៍រូបារម្មណ៍មានៈ ចក្ខុរូបារម្មណ៍ សោតរូបារម្មណ៍ ឃានរូបារម្មណ៍ ជីវ្ហារូបារម្មណ៍ កាយរូបារម្មណ៍។)

[២] WWW.google.com/Realism in Literature

នៅក្នុងស្នាដៃនិពន្ធបែបអណ្តែតអណ្តូងនិយនមរបស់អាល្លឺម៉ង់ ប៉ុន្តែវាមិនមានន័យថា មានអ្នកនិពន្ធណាម្នាក់ដែលយល់ច្បាស់ពី ចលនានេះ ឬក៏ចេះដឹងតាមរយៈការសិក្សានៅសាលានោះទេ  គឺវាគ្រាន់តែជាគំនិតដ៏សាមញ្ញ ដែលគេប្រើប្រាស់ ដើម្បីធ្វើការប្រឆាំងទៅនឹងចលនាមនោនិយម ឬឧត្តមគតិនិយមតែប៉ុណ្ណោះ ។

បន្ទាប់មកចលនានេះ ក៏បានលេចឡើងនៅក្នុងប្រទេសបារាំងនាឆ្នាំ ១៨២៦ ។ ដោយក្នុងនោះ គេបានដឹងថា មានអ្នកនិពន្ធម្នាក់ដែលបានសរសេរព្យាករណ៍ថា " វាគឺជាលទ្ធិមួយដែលដឹកនាំទៅរកការពិត ហើយវាមិនមែនជាស្នាដៃឯករបស់សិល្បៈនោះទេ ប៉ុន្តែវានឹងផ្តល់ជូននូវការពិតពីធម្មជាតិមក " ហើយវានឹងក្លាយជា " អក្សរសិល្ប៍នាសតវត្សរ៍ទី១៩ ឬក៏អក្សរសិល្ប៍ដែលឆ្លុះបញ្ចាំងនូវការពិត"  ទាំងនេះគឺជាពាក្យសម្តីរបស់អ្នកនិពន្ធ ប័រហ្គឺរូស (Borgerhoff) 1983 ។ ចំណែកអ្នកនិពន្ធ ហ្គូសស្តាវប្លង់ (Gustav Planche) លោកគឺជាអ្នកនិពន្ធម្នាក់ ដែលបានធ្វើការរិះគន់យ៉ាងខ្លាំងទៅនឹងចលនាអណ្តែតអណ្តូងនិយម ហើយត្រូវបានគេចាត់បញ្ចូល ទៅនឹងអ្នកនិពន្ធ នៅក្នុងចលនា " តថនិយម " នាឆ្នាំ ១៨៣៣ ហើយអ្វីដែលជាទស្សនៈរបស់លោក គឺមានភាពសមមូលទៅនឹងចលនាមួយទៀត ដែលហៅថា ធម្មជាតិនិយមជាពិសេសនោះ គឺទាក់ទងនឹងបទពិពណ៌នា ទាក់ទងនឹងសម្លៀកបំពាក់ និងប្រពៃណីទំនៀមទម្លាប់ ក្នុងស្នាដៃប្រលោមលោកបែបប្រវត្តិសាស្ត្ររបស់លោក ។ គាត់បាននិយាយថា " តថនិយមវាពិតជាមានការទាក់ទងហើយជាមួយនឹងដំណើររឿង  ដែលខែលទាំងឡាយត្រូវបានគេដាក់ពង្រាយនៅពីលើទ្វារប្រាសាទ នឹងគ្រឿងឧបករណ៍សឹកដ៏ទៃទៀត ដែលត្រូវបានគេចារឹកនៅលើជញ្ជាំងប្រាសាទនោះ ព្រមទាំងប្រវត្តិរឿងរ៉ាវស្នេហាមួយ " នៅក្នុងស្នានដៃរឿង Moralité de la poesie នៅក្នុងសៀវភៅ Revue des deux mondes 4th ser.1835, 205។  តថនិយមនៅក្នុងពេលនោះ គឺគ្រាន់តែជាលក្ខណៈ ឬជាទ្រង់ទ្រាយមួយ ដែលអ្នកនិពន្ធបានប្រើប្រាស់នៅក្នុងស្នាដៃរបស់ពួកគេ ហើយរហូតមកដល់សព្វថ្ងៃនោះ យើងទាំងអស់គ្នាបានហៅលក្ខណៈនោះថាជា " ភាពអណ្តែតអណ្តូងនិយម " ទៅវិញ ដូចជាស្នាដៃរបស់អ្នកនិពន្ធ ហ៊ុយហ្គោ (Hugo), ស្កុត (Scott), និង មេរីមេ (Merimee)ជាដើម ហើយដែលចលនាតថនិយមនោះ វាបានលេចរូបរាងយ៉ាងពិតប្រាកដទៅវិញ នៅក្នុងសម័យកាលនៃអ្នកនិពន្ធ បាល់ហ្សាក់ (Balzac) និង មុយហ្គឺ *(Murger)* នៅពេលបន្ទាប់មក ។ ចំណែកឯអ្នកនិពន្ធ ឆាំផ្លឺរី *(Champfleury)* នៅក្នុងឆ្នាំ ១៨៥៧ លោកបានបោះពុម្ពកម្រងអត្ថបទមួយ ដែលមានចំណងជើងថា Le realism ក្នុងខណៈពេលដែលមិត្តរបស់គាត់ម្នាក់ទៀត ឌុយរ៉ង់ទី *(Duranty )* បានសរសេរពីកម្រងរឿងរំលឹកឡើងវិញ ក្នុងអំឡុងឆ្នាំ១៨៥៦-៥៧ ដែលឆ្លុះបញ្ចាំងឱ្យឃើញនូវលក្ខណៈតថនិយមផងដែរ ។ ស្របពេលជាមួយនោះដែរ ក៏មានអ្នកនិពន្ធជាច្រើន ដែលបានសរសេរស្នាដៃ ឆ្លុះបញ្ចាំងអោយឃើញនូវចលនាតថនិយមដូចជាអ្នកនិពន្ធ មេរីមេ (Merimee), ស្តង់ដាល (Stendhal), បាល់ហ្សាក់ (Balzac), ម៉ូរីញ៉េ (Monnier) និង ហ្សាលដឺប៊ែរណា (Charles de Bernard) ដែលពួកគេទាំងនោះហើយ ជាអ្នកស្ថាបនិកនៃចលនាតថនិយមនេះតែម្តង ។ ក្រោយមកទៀតក៏មានអ្នកនិពន្ធ ឌុយម៉ាស់ (Dumas)  ដែលគាត់ទទួលការបណ្តុះបណ្តាលពីសាលា ។ ថ្វីបើអ្នកនិពន្ធ ផ្លឺប៊ែរ (Fleubert) ដែលជាអ្នកនិពន្ធតថនិយមស្រករក្រោយក៏ដោយ ក៏លោកពុំបានដើរគ្រាប់តាមគម្រូ ឬគំនិតស្តីពីតថនិយមរបស់អ្នកនិពន្ធស្រករមុនសម្រាប់ស្នាដៃរបស់លោកដែរ ។ នៅមានចំណុចដែលគួរអោយកក់សម្គាល់ថា មានការពុំពេញចិត្តមួយបានកើតឡើង ស្តីកិច្ចព្រមព្រៀងឯកស័ព្ទ នៅក្នុងការពិភាក្សាគ្នា នាដំណាក់កាលមួយចំពោះលក្ខណៈសំខាន់ៗនៃចលនាតថនិយម ។ ដោយក្នុងនោះ មានការមិនយល់ព្រមជាច្រើន ហើយបានលើកឡើងនូវគំនិតអវិជ្ជមាន និងការរិះគន់ជាច្រើន រហូតដល់ស្នាដៃរឿងរបស់អ្នកស្រី បូវ៉ារី (Madame Bovary) របស់អ្នកនិពន្ធ ផ្លូប៊ែរ (Fleubert) ត្រូវលេចឡើងនៅឆ្នាំ១៨៥៧ នៅប្រទេសបារាំង ។

តែទោះបីជាយ៉ាងណាក៏ដោយ ក៏យើងត្រូវតែទទួលស្គាល់ថា ចលនាតថនិយម ពិតជាបានកើតមាន និងទទួលភាពល្បីល្បាញនៅក្នុងប្រទេសបារាំងយ៉ាងប្រាកដមែន ។ ចំណែកនៅប្រទេសអង់គ្លេសវិញ ពុំមានឈ្មោះនៃចលនានេះទេ មុនពេលស្នាដៃរបស់អ្នកនិពន្ធ *ហ្សកម៉ូរ៉េ (George Moore)* និង ហ្សកហ្គាស៊ីង *(George Gassing) បានសរសេរ។* ក្រោយមកទៀតបញ្ញត្តិ " តថនិយម " (Realism) " តថ " (Realist) ក៏ត្រូវបានកើតឡើងនៅក្នុងស្នាដៃរបស់អ្នកនិពន្ធ បាល់ហ្សាក់ *(Balzac)* ជាដំបូងនៅឆ្នាំ ១៨៥៣ ហើយនឹងអ្នកនិពន្ធ *ថាក់ឃើរី (Thackeray)* បានហៅពាក្យទាំងពីរនេះថា " ជាតុដ៏សំខាន់នៃការសិក្សាពីតថនិយម " នៅក្នុងឆ្នាំ១៨៥១ ។ ហ្សកហង់រីឡឺវេស (Goegrer Henry Lewes) គឺជាអ្នករិះគន់ជនជាតិអង់គ្លេសដំបូង ដែលបានស្នើឱ្យមានការប្រើប្រាស់ពាក្យថា "តថនិយម" (Realism) យ៉ាងជាច់អហង្កា។ ក្រោយមកទៀត តាមរយៈការពិនិត្យដ៏ល្អិតល្អន់មក គេក៏យល់ថា "តថនិយម គឺពិតជាមាននៅក្នុងសិល្បៈទាំងឡាយ" ហើយលោក ឡឺវេស(Lewes) ក៏បានធ្វើការប្រកាសថា "*តថនិយមគឺជាមូលដ្ឋានគ្រឹះនៃសិល្បៈទាំងអស់។* ឯអ្នកនិពន្ធ *ថាក់ឃើរី* (Thackeray) វិញយល់ថា " *អ្នកនិពន្ធប្រលោមលោកម្នាក់គឺជាគ្រូបង្រៀន ដែលបង្ហាញអោយឃើញនូវការពិត* " ស្របពេលដែលអ្នកនិពន្ធ ឌីកកែន(Dickens) បានពោលថា " *អ្នកនិពន្ធប្រលោមលោកម្នាក់ អាចជាមនុស្សឧត្តមគតិនិយម ឬអណ្តែតអណ្តូងនិយមផងក៏ថាបានដែរ* " ហើយ " *ភាពរីកចម្រើននៅក្នុងអ្នកនិពន្ធប្រលោមលោកទាំងឡាយដែលបានយល់ពីស្មារតីនៃចលនាតថនិយម*"។ ឯការរិះគន់តថភាព គឺជាការសង្កេតទៅលើការពិត និងការពិពណ៌នាទៅលើព្រឹត្តិការណ៍ដែលបានកើតឡើង ដោយការបង្ហាញពីតួអង្គដែលបានចូលរួមក្នុងព្រឹត្តិការណ៍នោះ នោះហើយគឺអ្វីដែលជាការលេចឡើង ជាលក្ខណៈតថនិយមនោះដូចជាស្នាដៃរបស់អ្នកនិពន្ធ *បាល់ហ្សាក់* (Balzac)ជាដើម[៣] ។

ជារួមមក លក្ខណៈតថនៅក្នុងរឿង គឺជាជារឿងរ៉ាវ ហេតុការណ៍ ព្រឹត្តិការណ៍ ឈ្មោះទីកន្លែង សកម្មភាព ប្រពៃណីទំនៀមទម្លាប់ ធម្មជាតិ ទាំងឡាយដែលមានពិនៅក្នុងសង្គមជាក់ស្តែង ហើយត្រូវបានអ្នកនិពន្ធលើកយកមកបញ្ចូលក្នុងស្នាដៃរបស់ខ្លួន ឬយកមកផ្សារភ្ជាប់ទៅនឹងដំណើររឿងរបស់ខ្លួន ដោយរួមផ្សំជាមួយនឹងមនោសញ្ចេតនារបស់អ្នកនិពន្ធផ្ទាល់តែម្តង។

# សិក្សារឿងកុលាបប៉ៃលិន

## ក.ជីវប្រវត្តិអ្នកនិពន្ធ:

លោក **ញ៉ុក ថែម** កើតនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩០៣ នៅឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។ បិតារបស់លោក ឈ្មោះ ញ៉ុំ រីឯមាតា ឈ្មោះ ហៀក ជាជាតិខ្មែរ ហើយជាកសិករនៅភូមិអូតាគី ឃុំជ្រៃស្រុក ខេត្តបាត់ដំបង។ គាត់មានប្អូនប្រុសម្នាក់នាម ញ៉ុក ហុល។ កាលពីកុមារភាព គឺក្នុងឆ្នាំ១៩១៣ លោកបានទៅរៀននៅវត្តពោធិវង្ស ស្រុកសង្កែ ខេត្តបាត់ដំបង។ លោកបានសិក្សាអក្សរសាស្ត្រជាតិ ក្នុងសំណាក់លោកគ្រូអាចារ្យសន ហើយបានសិក្សាព្រះធម៌វិន័យ ក្នុងសំណាក់លោកគ្រូសូត្រ អ៊ីវ ទូច នៅវត្តពោធិវង្ស។

នៅឆ្នាំ១៩១៨ លោកមានបព្វជ្ជា(បួស) ជាសាមណេរ ។ ក្នុងឋានៈជាសាមណេរនេះ លោកបានសិក្សាធម៌វិន័យ និងភាសាបាលី ក្នុងសំណាក់លោកគ្រូអាចារ្យផ្សេងៗ នៅខេត្តបាត់ដំបង ។ លោកក៏បានទៅសិក្សានៅបរទេសដែរ គឺក្នុងឆ្នាំ១៩១៩ លោកបានបន្តវិជ្ជានៅក្រុងបាងកក ប្រទេសថៃ ។ លោកបានជាប់សញ្ញាប័ត្រធម្មសិក្សាជាន់ត្រី នៅកំឡុងឆ្នាំ១៩២១ និងជាប់សញ្ញាប័ត្រធម្មសិក្សាជាន់ទោ ក្នុងឆ្នាំ១៩២៣។ នៅឆ្នាំ១៩២៤ លោក

---

[៣] តាន់ សុគន្ធា និក្ខេបបទថ្នាក់បណ្ឌិត "ចលនាប្រលោមលោកខ្មែរសម័យទំនើបពីឆ្នាំ១៩៣៨-១៩៧០ ទំព័រ២៨-៣០ ឆ្នាំ២០១១

បានឧបសម្បទជាព្រះភិក្ខុ ហើយនៅក្នុងឆ្នាំដដែលនោះ លោកបានជាប់សញ្ញាប័ត្របរិយត្តិភាសាបាលី ទីមហា ៣ ប្រយោគ ។ លុះពីរឆ្នាំក្រោយមក គឺឆ្នាំ១៩២៦ លោកបានជាប់សញ្ញាប័ត្របរិយត្តិភាសាបាលី ទីមហា៤ ប្រយោគ ហើយពីរឆ្នាំតមកទៀត(១៩២៨) លោកជាប់ទីមហា ៥ ប្រយោគ និងជាទីបញ្ចប់ លោកបានជាប់ទីមហា ៦ ប្រយោគ នៅក្នុងឆ្នាំ១៩២៩ ។ សូមបញ្ជាក់ថា នៅប្រទេសថៃ ការសិក្សាភាសាបាលី មានសរុបទាំងអស់ ៩ ប្រយោគ (ជាន់ ឬ កម្រិត) ដែលប្រយោគទី៩ ជាប្រយោគខ្ពស់បំផុត(ថ្នាក់បណ្ឌិត) ។ លោកបាន លាចាកសិក្ខាបទមកជាគ្រហស្ថ នៅឆ្នាំ ១៩៣៦ ។

ពេលលោកទៅសិក្សានៅប្រទេសថៃ លោកក៏បានធ្វើការនៅទីនោះដែរ ។ លោកធ្វើជាគ្រូបង្រៀនភាសាបាលី នៅទីក្រុងបាងកក ចាប់ពីគ.ស.១៩២៧ ទៅទល់នឹង គ.ស.១៩៣០ ទើបត្រឡប់មកកាន់ទីក្រុងភ្នំពេញវិញ ដោយចូលធ្វើជាសមាជិកគណៈកម្មាការប្រែព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ។ នៅឆ្នាំ១៩៣៨ លោកធ្វើការនៅព្រះរាជបណ្ណាល័យកម្ពុជា មានមុខងារជាអ្នកចាត់ចែង បោះពុម្ពផ្សាយសៀវភៅផ្សេងៗ និងទស្សនា វដ្តីកម្ពុជសុរិយា។ នៅឆ្នាំបន្ទាប់មក(១៩៣៩) លោកបានធ្វើជាតំណាងសម្តេចព្រះនពត្តមសុជាតេ និងជាអធិបតីពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ជាមួយតំណាងផ្សេងៗទៀត លោកបានទៅរៀបចំកម្មវិធីសិក្សា និងពិធីសម្ពោធន៍ពុទ្ធសាសនបណ្ឌិត្យនៅក្រុងហ្លួងព្រះបាង និងក្រុងវៀងច័ន្ទ នាប្រទេសលាវ ។ ឆ្នាំ១៩៤២ លោកបានទៅសម្ពោធមន្ទីរសាសនបណ្ឌិត្យខេត្តឃ្លាំង ប្រទេសវៀតណាមភាគខាងត្បូង និង ឆ្នាំ១៩៤៣ លោកជាតំណាងរៀបចំកម្មវិធីសិក្សាសម្រាប់ពុទ្ធសាសនបណ្ឌិត្យ នៅខេត្តប៉ាក់សេ ប្រទេសលាវ ។

លោក**ញ៉ុក ថែម** បានធ្វើជាសាស្ត្រាចារ្យខ្មែរនៅថ្នាក់ទី ៥ នៃសាលាគរុវិជ្ជានៅឆ្នាំ ១៩៤៥ ។ នៅឆ្នាំ ១៩៤៦ លោកធ្វើការនៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ និងជាសាស្ត្រាចារ្យ នៅវិទ្យាល័យស៊ីសុវត្ថិទៀតផង។ ប៉ុន្តែនៅឆ្នាំ១៩៥០ លោកបានលាឈប់ពីពុទ្ធសាសនបណ្ឌិត្យ ចូលមកបម្រើក្រសួងសិក្សាធិការជាតិក្រោយពេលដែលបារាំងផ្ទេរវិទ្យាល័យស៊ីសុវត្ថិ មកជាសម្បត្តិជាតិ ហើយលោកធ្វើជាសាស្ត្រាចារ្យ ជាប់សន្សារហូតមក។ ប្រាំមួយឆ្នាំក្រោយមក គឺនៅឆ្នាំ ១៩៥៦ លោកសុំផ្លាស់ទៅធ្វើជាសាស្ត្រាចារ្យខ្មែរ នៅវិទ្យាល័យមុនីវង្ស នាក្រុងបាត់ដំបង ។ ប៉ុន្តែក្នុងឆ្នាំ ១៩៥៨ លោកបានផ្លាស់ទៅធ្វើការនៅវិទ្យាស្ថានជាតិគរុកោសល្យ នាក្រុងភ្នំពេញវិញ ក្នុងឋានៈលោកជាសាស្ត្រាចារ្យផង និងអ្នកស្រាវជ្រាវ ឯកសារអក្សរសាស្ត្រខ្មែរ នៅវិទ្យាស្ថាននោះផង ។ លោកក៏ជាសាស្ត្រាចារ្យខ្មែរនៅសាលាភូមិន្ទរដ្ឋបាល ។

កាលលោកទៅសិក្សា និងធ្វើការនៅប្រទេសថៃ លោកបាននិពន្ធសៀវភៅជាភាសាថៃ ឬបាលីថៃ។ ស្នាដៃទាំងនោះ មានជាអាទិ៍៖ នមោកថា នានាជាតក វណ្ណនា ធម្មនិទ្ទេសភាគ១ ទេវតាភាសិត និងពុទ្ធភាសិត។ ក្រៅពីនេះលោកមានស្នាដៃជាភាសាខ្មែរយ៉ាងច្រើនដូចជា៖

- ពុទ្ធប្បវត្តិសង្ខេប
- អនុពុទ្ធប្បវត្តិ ភាគ១-២
- ប្រជុំភាសិត ភាគ១-២
- មហាវេស្សន្តរជាតក
- ប្រជុំពុទ្ធភាសិត
- ជាតិសាសនាព្រះមហាក្សត្រ
- រឿងបិសាចស្នេហា (ប្រលោមលោកបោះពុម្ពឆ្នាំ១៩៤២)

- រឿងកុលាបប៉ៃលិន (ប្រលោមលោកបោះពុម្ពក្នុងឆ្នាំ១៩៣៦ ឬ១៩៤៣)
- ឯកសហារាត្រី (ភាគខ្លះ ប្រែ)
- ចូឡវេទល្លសូត្រ (ប្រែ)
- វិធីប្រតិបត្តិធម៌
- ពន្លឺអាស៊ីទ្វីប (ប្រែ)
- បញ្ញាសជាតកសង្ខេប ភាគ១-២[៤]។

### ខ.សង្ខេបរឿងកុលាបប៉ៃលិន:

រឿង កុលាបប៉ៃលិន ចាប់ផ្តើមរៀបរាប់ពីដំណើរជីវិតរបស់យុវជនម្នាក់ឈ្មោះចៅចិត្រ។ ចៅចិត្រទើបនឹងបានប្រឡងជាប់ប្រកាសនីយប័ត្រ តាចឹមជាបុរសពោះម៉ាយ ជាឪពុករបស់ចៅចិត្រ គាត់មានជំងឺជាទម្ងន់ហើយបានស្លាប់ទៅ។ ចៅចិត្រត្រូវកំព្រាទាំងឪពុកម្តាយ ហើយមានជីវភាពក្រីក្រគ្មានទ្រព្យសម្បត្តិទេ។ ក្នុងពេលដែលជីវិតយុវជននោះតែលតោល លោកគ្រូពេទ្យស្អាត ដែលធ្លាប់បានជួយព្យាបាលឪពុកចៅចិត្រ បានជួយយុវជននោះ ដោយបានសរសេរសំបុត្រមួយច្បាប់ទៅឱ្យឪពុកមាររបស់គាត់ ដែលជាថៅកែត្បូងនៅប៉ៃលិន ឈ្មោះហ្លួងរតនសម្បត្តិ ឱ្យទទួលយកចៅចិត្រទៅធ្វើការនៅកន្លែងជីកត្បូង។ ចៅចិត្របានធ្វើដំណើរទៅប៉ៃលិន យកសំបុត្រនោះ ទៅប្រគល់ជូនដល់ដៃលោកហ្លួងរតនសម្បត្តិ។ ហ្លួងរតនសម្បត្តិ ក៏ទទួលយល់ព្រមឱ្យចៅចិត្រធ្វើការជាកម្មករជីកត្បូង។ កូនស្រីរបស់ហ្លួងរតនសម្បត្តិ ឈ្មោះឃុននារី នាងជានារីម្នាក់មានចរិតឆ្មើងឆ្មៃ និងចូលចិត្តនិយាយទ្រគោះពេលឃើញរូបរាងដ៏ស្គមរបស់ចៅចិត្រ ហើយក៏សម្តែងការមិនពេញចិត្តភ្លាមៗ។ ចៅចិត្របានតវ៉ាធ្វើឱ្យនារីកាន់តែខឹង។

ក្នុងរយៈពេលធ្វើការងារ និងរស់នៅជាមួយហ្លួងរតនសម្បត្តិ ចៅចិត្រខិតខំធ្វើការណាស់ រហូតដល់បានជាទីពេញចិត្តនៃកម្មករទាំងអស់ ព្រមទាំងលោកហ្លួងរតនសម្បត្តិទៀតផង។ ចៅចិត្រតែងនឹកឃើញជានិច្ចនូវពាក្យបណ្តាំឪពុក " អត្តាហិអត្តនោនាថោ " (គឺខ្លួនទីពឹងខ្លួន)។ ចៅចិត្រមានអារម្មណ៍មួយ គឺនឹកគួចទៅរកឃុននារី ព្រោះនាងមានឫកខ្ពស់ និងគួរឱ្យជជែកតតាំង តែគេក៏ដឹងថា នាងជាកូនអ្នកមានទ្រព្យសម្បត្តិ ចំណែកខ្លួនគេជាយុវជនកំព្រាក្រីក្រ។ ចំណែកនាងឃុននារី វិញ ពេលនោះ ក៏ចាប់អារម្មណ៍លើចៅចិត្រណាស់ដែរ ព្រោះកម្មកររូបនេះហាក់ដូចជា មិនចេះខ្លបខ្លាចនាងដូចកម្មករដទៃសោះ ហើយនិយាយស្តីជាមនុស្សមានការយល់ដឹងផង។ ក្នុងរាត្រីមួយអ្នកទាំងពីរបានអង្គុយជជែកគ្នាលេងយ៉ាងស្លូតបូតក្រោមពន្លឺព្រះច័ន្ទ។

ថ្ងៃមួយពេលចៅចិត្រលីចបទៅធ្វើការ គេបានជួបលោកហ្លួងរតនសម្បត្តិ និងឃុននារី កំពុងរៀបចំចេញដំណើរទៅស្រុកសង្កែ តែតាសុនជាអ្នកបើកបររថយន្តបញ្ឆេះរថយន្តមិនឆេះសោះ។ ចៅចិត្របានជួយជួសជុលរថយន្តនោះឱ្យមានដំណើរការធម្មតា។ ពេលនោះ ដោយតាសុនជាប់រវល់ គាត់ក៏បានសុំលោកហ្លួងរតនសម្បត្តិ ឱ្យចៅចិត្របរឡានជំនួសគាត់បានមួយថ្ងៃ លោកក៏យល់ព្រម ចៅចិត្រក៏បរឡានជូនលោក និងឃុននារីទៅដល់ស្រុកសង្កែ។ នៅស្រុកសង្កែ នាងឃុននារីបានធ្វើបាបចៅចិត្រ ដោយឱ្យយួរកន្ត្រកដើរតាមនាងចូលផ្សារ ហើយទិញឥវ៉ាន់យ៉ាងច្រើន។ ពេលថ្ងៃ គេទាំងអស់ត្រូវត្រឡប់មកប៉ៃលិនវិញជាមួយយុវជនម្នាក់ទៀតជាបាឡាត់ស្រុកសង្កែ។ ចៅចិត្រ មិនសប្បាយចិត្តទេ ពេលឃើញលោកបាឡាត់ និងឃុននារីស្និទ្ធស្នាលនឹងគ្នា។ ចិត្របានបើកឡានឱ្យធ្លាក់ជង្ហុក ធ្វើឱ្យបាឡាត់និងឃុននារីខឹងសម្បាយ៉ាងខ្លាំង។ ទីបំផុតរថយន្តខូចលែងទៅមុខ។ គេត្រូវឈប់កណ្តាលព្រៃរង់ចាំលុះត្រាមានរថយន្តណាមកតាមផ្លូវនោះ ទើបអាចសណ្តោងទៅបាន។ លោកបាឡាត់បានឈ្លោះប្រកែកយ៉ាង

---

[៤] https://km.wikipedia.org/wiki/ញ៉ុក_ថែម

ខ្លាំងជាមួយថៅចិត្រ តែលោកហ្លួងរតនសម្បត្តិបានសម្រុះសម្រួល រួចបង្គាប់ឱ្យរៀបចំដាំបាយបរិភោគ។ ពេលនោះកម្លោះទាំងពីរខិតខំផ្គាប់ផ្គុន យុននារីយ៉ាងខ្លាំង តែថៅចិត្របានលទ្ធផលល្អជាង។

ពេលយប់ លោកហ្លួងរតនសម្បត្តិបានសម្រាន្ត លោកបាឡាត់ និងយុននារីអង្គុយជជែកគ្នា ឯថៅចិត្រអង្គុយជក់បារីម្នាក់ឯងដោយទុក្ខព្រួយ ព្រោះគេប្រាកដក្នុងខ្លួនថា បានស្រឡាញ់យុននារីដែលជាកូនអ្នកមាន។ នារីបានយកកាំភ្លើងមកប្រគល់ឱ្យថៅចិត្រអង្គុយយាមពេលលោកបាឡាត់ចូលដេក ចិត្របានអង្វរនាងឱ្យនៅអង្គុយជជែកគ្នាលេង។ ពេលនោះចិត្រ បាននិយាយបញ្ឆិតបញ្ឆៀងឱ្យនារីដឹងថា អ្នកស្រឡាញ់នាង។ នារីដឹងហើយចង់ឆ្លើយប្រាប់ចិត្រថា នាងក៏ស្រឡាញ់ថៅចិត្រដែរ តែនាងខ្មាសមិនអាចនិយាយបាន។ ពេលនារីចូលគេង ថៅចិត្របានឃើញពន្លឺភ្លើងជាច្រើនឯនាយវាលព្រៃ ហើយកាន់តែខិតមកជិត។ យុននារីបានដាស់ឪពុក និងលោកបាឡាត់។ គេបានកំណត់ថា ភ្លើងនោះជាភ្លើងចោរព្រៃ ហើយក៏ត្រៀមប្រយុទ្ធ៖ លោកបាឡាត់ បានចូលពួនក្រោមឡានលោករតនសម្បត្តិនៅក្បែររថយន្ត ថៅចិត្រ និងយុននារី នៅក្បែរដើមស្រឡៅ។ ការប្រយុទ្ធបានប្រព្រឹត្តទៅ ដោយខាងចោរមានប្រៀបជាងព្រោះពួកចោរមានគ្នាច្រើន។ ពេលដឹងថា នៅសល់គ្រាប់កាំភ្លើងតែមួយគ្រាប់ ថៅចិត្រអោបនារីជាប់ ហើយនិយាយប្រាប់នារីត្រង់ថា អ្នកស្រឡាញ់នារី ឯនាងក៏សារភាពវិញដែរ។ ពេលនោះថៅចិត្រត្រូវរបួស ហើយសន្លប់បាត់ស្មារតី។

ថៅចិត្របានដឹងខ្លួនឡើងនៅក្នុងបន្ទប់របស់ខ្លួននាថ្ងៃបន្ទាប់ ដោយមានយុននារីអង្គុយក្បែរនោះផង។ យុននារីបាននិយាយប្រាប់ថៅចិត្រថា ពេលកំពុងមានគ្រោះថ្នាក់នោះ តាសុន ព្រមទាំងកម្មករជាច្រើន បានទៅជួយទាន់ពេល ហើយយកចិត្រមកព្យាបាលភ្លាមៗ។ ថៅចិត្របានសម្ដែងការព្រួយបារម្ភរបស់ខ្លួនក្នុងរឿងស្នេហា តែយុននារីអង្គុយអះអាងថា នាងស្រឡាញ់ចិត្រពិតប្រាកដ ហើយឪពុកនាង ក៏ពេញចិត្តថៅចិត្រណាស់ដែរ។ ក្រោយពេលបានជាសះស្បើយ ថៅចិត្រ ត្រូវបានតែងតាំងជាអ្នកគ្រប់គ្រងការងារ ជំនួសលោកហ្លួងរតនសម្បត្តិ ហើយស្នេហារបស់យុវជនទាំងពីរ ក៏កាន់តែរីកធំធាត់ជាលំដាប់។

ថ្ងៃមួយពេលថៅចិត្រ និងយុននារីកំពុងអង្គុយជជែកគ្នាក្នុងបន្ទប់ធ្វើការ លោកបាឡាត់បាននាំជនម្នាក់ឈ្មោះ ផាន់ មកជួបលោកហ្លួងរតនសម្បត្តិ ហើយបានប្រាប់ថា ជននោះជាថៅកែ មករកទិញត្បូង។ ក្រោយពេលពិនិត្យត្បូងរួចហើយ ថៅកែផាន់បានសុំទៅទស្សនាកន្លែងជីកត្បូងទៀត។ លោកហ្លួងរតនសម្បត្តិ និងថៅចិត្របានជូនដំណើរថៅកែផាន់ដើរមើលកន្លែងជីកត្បូង។ លោកបាឡាត់នៅក្នុងផ្ទះជាមួយយុននារី។ ពេលនោះ លោកបាឡាត់បាននិយាយសុំសេចក្ដីស្នេហ៍យុននារី តែនាងមិនព្រម លោកបាឡាត់ ក៏បានចាប់បង្ខំយុននារី ថៅចិត្រមកទាន់ ហើយជួយយុននារី នារីបានប្រាប់ឪពុកនាង លោកហ្លួងរតនសម្បត្តិក៏បណ្ដេញលោកបាឡាត់ចេញពីផ្ទះរបស់លោកភ្លាមៗតែម្ដង។

លុះវេលាយប់ថ្ងៃនោះ បាឡាត់និងនាយផាន់ បាននាំក្រុមចោរ មកប្លន់ផ្ទះហ្លួងរតនសម្បត្តិ។ ក្រុមកម្មករបានតស៊ូជាមួយក្រុមចោរយ៉ាងស្វិតស្វាញ ឯថៅចិត្របានសម្លាប់នាយផាន់ និងបាឡាត់ ជួយជីវិតហ្លួងរតនសម្បត្តិ និងយុននារី។ ក្រោយពីកើតហេតុនោះ ធ្វើឱ្យលោកហ្លួងរតនសម្បត្តិ កាន់តែពេញចិត្តថៅចិត្រ ហើយបានយល់ចិត្តយុវជនទាំងពីរ គាត់បានក៏រកពេលវេលាផ្សំផ្គុំយុននារីឱ្យថៅចិត្រ រួចប្រគល់ការងារព្រមទាំងទ្រព្យសម្បត្តិឱ្យថៅចិត្រកាន់កាប់ជំនួសលោក។

**គ.បទនិពន្ធ:**

តាមរយៈចំណងជើងរឿង "កុលាបប៉ៃលិន" ធ្វើឱ្យយើងគិតដល់ការបង្ហាញអំពីនារីក្រមុំម្នាក់នៅប៉ៃលិនដែលគេពិបាកនឹងលូកលាន់ ព្រោះនៅក្នុងនិមិត្តរូបារម្មណ៍ខ្មែរ ផ្កាកុលាបដែលទងវាមានបន្លា គេប្រៀបប្រដូចទៅ

នឹងនារី ដែលមានឋានៈ ឬវណ្ណៈខ្ពស់ ហើយមានចរិតឆ្មើងឆ្មៃ តឹងតែង ដែលកម្លោះអ្នកក្រីក្រ តូចទាប ពិបាកនឹងប៉ង ប្រាថ្នាណាស់។ ស្របតាមរូបារម្មណ៍នោះ លោក ញ៉ុក ថែម បានបង្ហាញថាតួអង្គយុននារី ជាកូនមហាសេដ្ឋីត្បូង និងប្រកបដោយឫកពារ របៀបនោះមែន "....ដួងភ្នែកប្រកបដោយទឹកដមគួរជាទីចាប់ចិត្តស្នេហា តែមានឫកពារ ឆ្មើងឆ្មៃបន្តិច"។ តាមដំណើររឿង យើងឃើញថា រឿងសំខាន់ ដែលអ្នកនិពន្ធ បានលើកមកនិយាយនោះ គឺមិនមែន តែរឿងស្នេហារបស់កម្លោះក្រីក្រ កំព្រីកំព្រាម្នាក់ចំពោះយុននារីនោះទេ។ ជាការពិតណាស់ ដែលក្នុងរឿងស្នេហា នោះ ចៅចិត្រ គិតដល់រឿងឧបសគ្គទាំងឡាយ ដូចជា បេះដូងរឹងរូសរបស់យុននារី និងពូជពង្សរបស់នាង តែផ្ទុយ ទៅវិញ អ្នកនិពន្ធមិនបង្ហាញថា យុននារីរឹងរូស ឬប្រកាន់ពូជពង្ស... ឯឪពុកនាងទៀតសោតរឹតតែងាយ។ ដូចនេះ រឿងស្នេហាចៅចិត្រ និងយុននារី មិនមែនជារឿងស្នេហាកំសត់ព្រាត់ប្រាសដូចស្នេហា ទុំទាវឡើយ។

បើពិនិត្យទៅលើរបៀបរបបទុកដាក់កូនចៅក្នុងសង្គមខ្មែរ ដែលនិយមសម្លឹងមើលទ្រព្យសម្បត្តិជាមុននោះ ស្នេហាចៅចិត្រ និងយុននារី អាចចាត់ទុកថាជាស្នេហាមួយដែលមិនរើសអើងវណ្ណៈនៅប៉ៃលិន ក្នុងដើមសតវត្សរ៍ ទី២០នេះ។ តាមខ្លឹមសាររឿង យើងយល់ថា ប្រវត្តិស្នេហានោះ គឺជាបទនិពន្ធរឿង "កុលាបប៉ៃលិន" របស់អ្នកនិពន្ធ ញ៉ុក ថែម ។

### ឃ.គំរោងនិពន្ធ:

លោក ញ៉ុក ថែម បានតាក់តែងរឿង " កុលាបប៉ៃលិន " តាមបែបជារឿងប្រលោមលោកទំនើប ដោយមាន ចែកជាវគ្គខ្លីៗ ទាំងអស់មាន ៦វគ្គ ដែលសរសេរជាចំណងជើងតាមវគ្គនីមួយៗមានដូចជា: រឿង កុលាបប៉ៃលិន វគ្គ ទី១ " ជីវិតរបស់ក្មេងកំព្រា " វគ្គទី២ " ការធ្វើដំណើរទៅបរប៉ៃលិន " វគ្គទី៣ " ចៅចិត្រកើតគំនិតថ្មី " វគ្គទី៤ " ចោរកម្មកើតឡើងនាកណ្ដាលព្រៃស្ងាត់ " វគ្គទី៥ " សេចក្ដីស្នេហាកើតក្រោយឧប្បត្តិហេតុ " និងវគ្គទី៦ " គេហ ស្ថានរតនសម្បត្តិត្រូវចោរប្លន់ "។ល។ ក្នុងវគ្គទាំងនោះ រួចពីវគ្គមួយចូលទៅដល់វគ្គមួយទៀត អ្នកនិពន្ធបានបង្ហាញ នូវដំណើររឿង ដែលមានទំនាក់ទំនងគ្នាជាហូរហែរ ដោយគ្មានអាក់អួល និងគ្មានលាក់អាថ៌កំបាំងឡើយ ដូចជា ភាពក្រីក្រ សេចក្ដីស្នេហា អសន្តិសុខ ទីបំផុតអ្នកនិពន្ធដោះស្រាយរួចទាំងអស់។

### ខ.តថភាពតាមរយៈស្នាដៃ "កុលាបប៉ៃលិន"

រឿងកុលាបប៉ៃលិន ដែលលោក ញ៉ុក ថែម បានតាក់តែងឡើងតាំងពីឆ្នាំ ១៩៣៦។ យើងឃើញថាទោះជា ស្នាដៃនេះជាស្នាដៃទីមួយ ដែលសរសេរជាពាក្យរាយ ដែលមានការរចនាពាក្យពេចន៍ឃ្លាប្រយោគមានលក្ខណៈ ពេញលេញឥតខ្ចោះ តាមលក្ខណៈនៃភាសាអក្សរសិល្ប៍ មិនចាញ់ស្នាដៃរបស់អ្នកនិពន្ធ ដែលមានបទពិសោធន៍ ច្រើនក្នុងការសរសេរស្នាដៃពាក្យរាយឡើយ។ ពិសេសទៅទៀត ភាសាសន្ទនារបស់ អ្នកនិពន្ធត្រូវបានគេនិយមចូល ចិត្តហើយយកតម្រាប់តាម។ ក្រៅពីសមត្ថភាព ខាងការប្រើប្រាស់ភាសាអក្សរសិល្ប៍ លោក ញ៉ុក ថែម បានធ្វើឲ្យ កើតជារូបរាងនូវ គំនិតអ្នកនិពន្ធប្រជាប្រិយខ្មែរ ដោយលាតត្រដាងពីជីវភាពសាមញ្ញក្នុងសង្គមខ្មែរ តួអង្គមាន លក្ខណៈជាមនុស្សខ្មែរ រស់ក្នុងជីវភាពបែបខ្មែរ មានរូបសម្បត្តិ អត្តចរិត និងផ្នត់គំនិតជាខ្មែរ ទីកន្លែងរឿងក៏ស្ថិតក្នុង ប្រទេសខ្មែរ ហើយធម្មជាតិក៏សុទ្ធសឹងមានពិតក្នុងប្រទេសខ្មែរ។ យើងបានចាត់ទុក ស្នាដៃនេះ ក្នុងចលនា អក្សរសិល្ប៍ខេមរនិយម។ តែដោយការបង្ហាញពីជីវភាពមួយចំនួន មានលក្ខណៈដូចជាគ្រាន់តែមានតាមគំនិតរបស់ អ្នកនិពន្ធ ហើយមិនដូចការពិតមែនទែន ក្នុងសង្គមដូចជាបង្ហាញពីជោគជ័យក្នុងជីវិតចៅចិត្រនោះ ទើបមាន ទស្សនៈមួយចំនួន បានរិះគន់លោក ញ៉ុក ថែម។

ពួកអ្នកសង្គមនិយម គេចាត់ទុកលោក ញ៉ុក ថែម ជាអ្នកនិពន្ធប្រតិកិរិយា។ ដូចនេះហើយ រឿងកុលាប ប៉ៃលិន ដែលពីសង្គមសម័យមុនត្រូវបានគេបញ្ចូលក្នុងកម្មវិធីសិក្សានៅមធ្យមសិក្សា ត្រូវគេលុបចោលទៅវិញក្នុង

សម័យសង្គមនិយម។ ចំណុចប្រតិកិរិយាដែលអ្នកសង្គមនិយមកំណត់គឺគំនិតផ្សះផ្សាវណ្ណៈដែលផ្ទុយ ទាំងស្រុងពីលទ្ធិម៉ាក្ស។

## ខ.១. ទីកន្លែងរឿង

ក្នុងការតាក់តែងស្នាដៃ លោកញ៉ុក ថែម បានផ្សារភ្ជាប់ជានិច្ចទៅនឹងឈ្មោះទីកន្លែងដែលមានពិតនៅប្រទេសកម្ពុជា។ ដំណើររឿងទាំងមូលកើតឡើងនៅខេត្តបាត់ដំបង គឺនៅស្វាយប៉ោ (ផ្សារវិលក្នុងទីរួមខេត្តបាត់ដំបង) នៅប៉ៃលិន (កន្លែងជីកយកត្បូងពេជ្រសំខាន់បំផុតនៃប្រទេសកម្ពុជា) នៅទីរួមស្រុកសង្កែនិងតាមផ្លូវពីទីរួមស្រុកសង្កែ មកប៉ៃលិន កាត់តាមភូមិភ្នំសំពៅ ភូមិស្ទឹង ភូមិព្រៃផ្ដៅជាដើម។ យើងឃើញថា ក្នុងនិម្មិតកម្ម ទីកន្លែងរឿងអ្នកនិពន្ធយកចិត្តទុកដាក់បង្ហាញតាំងពីទីកន្លែងតូចតាចឡើងទៅ។ ឧទាហរណ៍: ទីលំនៅរបស់គ្រួសារចៅចិត្រនៅស្វាយប៉ោ។ មួយទៀតចំពោះនិម្មិតកម្មចំណងជើង អ្នកនិពន្ធបានភ្ជាប់នឹងឈ្មោះទីកន្លែងក្នុងរឿង តែម្ដង គឺ " កុលាបប៉ៃលិន " មានន័យថា "នារីដ៏ស្អាតនៅប៉ៃលិន"។ រឿងដែលអ្នកនិពន្ធយកចិត្តទុកដាក់តាំងពីកន្លែងតូចតាចឡើងទៅបែបនេះ គេអាចនិយាយបានថា មកពីអ្នកនិពន្ធមានស្រុកកំណើតនៅទីនោះ (លោក ញ៉ុក ថែម កើតនៅឃុំស្វាយប៉ោ) តែក៏អាចនិយាយថា មកពីទីកន្លែងទាំងនោះស្ថិតក្នុងភូមិសាស្ត្រសំខាន់ៗ នៃប្រទេសខ្មែរ ដោយខេត្តបាត់ដំបង ជាតំបន់កសិកម្មសំខាន់បំផុត ហើយប៉ៃលិនជាតំបន់ត្បូងពេជ្រដ៏មានតម្លៃ។ ហេតុនេះហើយទើបបាត់ដំបងនិងប៉ៃលិន ក្លាយជាប្រភពនៃប្រធានបទនៃការនិពន្ធបទចម្រៀង និងស្នាដៃជាច្រើនទៀត ក្រៅពីរឿងកុលាបប៉ៃលិននេះ។

## ខ.២. ការបង្ហាញពីធម្មជាតិ:

យើងបាននិយាយក្នុងផ្នែកតំណែងនិពន្ធថា លោកញ៉ុក ថែម មិនសូវពូកែរៀបរាប់ពីធម្មជាតិទេ។ តែទោះជាយ៉ាងនេះក៏ដោយក៏យើងអាចស្គាល់ធម្មជាតិនៃប្រទេសកម្ពុជា តាមរយៈស្នាដៃនេះ ហើយគឺធម្មជាតិទាំងនោះហើយដែលបង្ហាញលក្ខណៈតថៈក្នុងស្នាដៃ ព្រោះវាជាធម្មជាតិដែលមានពិតមិនមែនដោយការប្រឌិតរបស់អ្នកនិពន្ធដែរ។ អ្នកនិពន្ធបានពិពណ៌នាធម្មជាតិទៅតាមស្ថានភាពនៃរឿង។ ឧទាហរណ៍: ក្នុងស្ថានភាពអណ្ដែតអណ្ដូងក្នុងរឿងទុក្ខព្រួយ និងក្នុងពេលបណ្ដែតអារម្មណ៍ អ្នកនិពន្ធបានពិពណ៌នាអំពី ធម្មជាតិនាពេលរាត្រី មានព្រះច័ន្ទមានតារា មានជំនោរត្រជាក់។ល។ ឯនៅពេលធ្វើដំណើរ អ្នកនិពន្ធបានរៀបរាប់ពីទេសភាពតាមដងផ្លូវមានព្រៃភ្នំមានផ្លូវឡើងចុះមានធម្មជាតិប្លែកៗ គួរឲ្យចាប់អារម្មណ៍។ និយាយរួម គេអាចស្រមៃឃើញធម្មជាតិដែលពោរពេញទៅដោយលក្ខណៈប្រលោមចិត្ត នៅប្រទេសកម្ពុជា តាមរយៈរឿងកុលាបប៉ៃលិន ម្យ៉ាងទៀតអ្នកនិពន្ធក្រោយៗមកក៏បានអនុវត្តន៍តាមគំរូនេះ ដោយផ្សារភ្ជាប់មនោសញ្ចេតនាខ្លួនជាមួយនឹងធម្មជាតិប្លែកៗនៃទឹកដីជាតិខ្លួនផងដែរ។

## ខ.៣.ការបង្ហាញជីវភាពសង្គម:

តាមដំណើរជីវិតរបស់ចៅចិត្រ បាននាំយើងឲ្យជួប ស្គាល់នូវព្រឹត្តិការណ៍ទាំងឡាយដែលជាការឆ្លុះបញ្ចាំងពីតថភាពសង្គមខ្មែរ តាមរយៈរឿងកុលាបប៉ៃលិន។ ការជឿទៅលើទ្រឹស្ដីព្រះពុទ្ធសាសនា តាចឹម បានផ្ដែផ្ដាំកូនប្រុសនូវពាក្យចុងក្រោយ "អត្តាហិអត្តនោនាថោ " (គឺខ្លួនទីពឹងខ្លួន)។ ចៅចិត្រតែងនឹកឃើញជានិច្ចនូវពាក្យបណ្ដាំឪពុក។

### - អំពីជីវភាពប្រជាជន:

យើងឃើញថា ប្រជាជនខ្មែរសម័យនោះរស់នៅដោយខ្វះការជានាវ៉ាប់រង និងការឧបត្ថម្ភពីរដ្ឋអំណាច។ អ្នកនិពន្ធបានបង្ហាញជីវភាពបែបនេះតាមរយៈគ្រួសារចៅចិត្រ គឺឪពុកស្លាប់ដោយសារជំងឺរ៉ាំរ៉ៃ គ្មានទ្រព្យសម្បត្តិគ្មានការងារធ្វើ ត្រូវលក់កម្លាំងពលកម្មឲ្យនាយទុន។ តាមការពិពណ៌នារបស់ អ្នកនិពន្ធយើងអាចដឹងថានៅតំបន់

នោះ ក្រៅពីលក់កម្លាំងពលកម្មឲ្យថៅកែត្បូងប្រជាជននៅមានរបរកសិកម្ម ធ្វើស្រែ ចម្ការ និងលក់ដូរខ្លះៗនៅតាមផ្សារ។ ឯកម្រិតជីវភាពប្រហែលជាមិនខ្ពស់ទេ ព្រោះតាមការបង្ហាញរបស់អ្នកនិពន្ធ ឃើញថា គ្រួសារចៅចិត្រក្រីក្រខ្លាំងណាស់ ហើយសូម្បីហ្លួងរតនសម្បត្តិជាថៅកែត្បូង ក៏ជិះត្រឹមរថយន្តចាស់ ធ្វើដំណើរខូចតាមផ្លូវដែរ។ បើផ្អែកលើព្រឹត្តិការណ៍ជាក់ស្តែងក្នុងប្រវត្តិសាស្ត្រ យើងអាចសន្និដ្ឋានបានថា ប្រជាជនខ្មែរសម័យនោះ មានកម្រិតជីវភាពទាបណាស់ ព្រោះពេលនោះប្រទេសខ្មែរស្ថិតក្រោមអាណានិគមនិយមបារាំងដែលបានជំរិតយកពន្ធដារយ៉ាងធ្ងន់ធ្ងរពីប្រជាជនខ្មែរ។

- **អំពីសុវត្ថិភាពសង្គម:**

លោក ញ៉ុក ថែម បានបង្ហាញពីព្រឹត្តិការណ៍ទាក់ទងនឹងអំពើលួចឆក់ប្លន់ពីរដងក្នុងដំណើររឿងកុលាបប៉ៃលិន ដែរ។ លើកទីមួយនៅវគ្គទី៤ " ចោរកម្មបានកើតឡើងនៅកណ្តាលព្រៃស្ងាត់ " គឺពេលដែលចៅចិត្រ បើករថយន្តនាំហ្លួងរតនសម្បត្តិ យុននារី និងលោកបាឡាត់ ត្រឡប់មកផ្ទះវិញ ហើយត្រូវដេកផ្លូវព្រោះរថយន្ត ខូច។ លើកទីពីរ នៅវគ្គទី៦ " គេហដ្ឋានរតនសម្បត្តិត្រូវចោរប្លន់" គឺពេលដែលលោកបាឡាត់នាំក្រុមចោរមកប្លន់ផ្ទះលោកហ្លួងរតនសម្បត្តិ ក្រោយពេលដែលលោកសុំស្រឡាញ់យុននារីមិនបាន។ តាមរយៈការបង្ហាញ របស់អ្នកនិពន្ធយើងឃើញពីអំពើឆក់ប្លន់ មានទ្រង់ទ្រាយធំ ហើយពួកចោរមានគ្នាច្រើន និងមានកាំភ្លើងទៀត។ ទាំងនេះជាការបង្ហាញឲ្យយើងឃើញថា រដ្ឋអំណាចខ្វះសមត្ថភាពក្នុងការគ្រប់គ្រងប្រទេស នាំឲ្យពួកជនខិលខូចប្រមូលផ្តុំបានជាបក្សពួកដើរឆក់ប្លន់ប្រជាជនតាមអំពើចិត្ត ធ្វើឱ្យប្រទេសមានអសន្តិសុខអាយុជីវិតប្រជាជនត្រូវគម្រាមកំហែង។

- **រូបភាពអ្នកកាន់អំណាច**

តាមរយៈការបង្ហាញតួអង្គបាឡាត់ ដែលជាតំណាងឱ្យរដ្ឋអំណាចស្រុកសង្កែ យើងឃើញរូបភាពអ្នកកាន់អំណាចមួយបែបដែលធ្វើឲ្យយើងទាស់ចិត្ត។ បើតាមសម្លៀកបំពាក់ លោកបាឡាត់ បង្ហាញឲ្យយើងឃើញកម្រិតរស់នៅមួយបែបដែលខ្ពស់ឆ្ងាយដាច់ស្រឡះពីប្រជាជន ឯចរិតឫកពារ និងសម្តីបាឡាត់វិញ រឹតតែបង្ហាញនូវគម្លាតគ្នាយ៉ាងខ្លាំងរវាង អ្នកកាន់អំណាច និងប្រជាជន និងជាការបង្ហាញពីការមើលងាយមើលថោកដល់ ប្រជាជនពីសំណាក់អ្នកកាន់អំណាច ប្រការមួយទៀតដែលសំខាន់ គឺរដ្ឋអំណាចឃុបឃិតជាមួយចោរ ដឹកនាំចោរមកប្លន់ប្រជាជន ដូចលោកបាឡាត់ ដែលនាំចោរមកប្លន់ផ្ទះលោករតនសម្បត្តិ។ នៅប្រទេសកម្ពុជារឿងដែលគេសើចចំអកឲ្យរដ្ឋអំណាចរហូតដល់បច្ចុប្បន្ន គឺចោរនិងប៉ូលីស វាត្រូវតែគ្នា មានន័យថា អ្នកមានអំណាចយកអំណាចរបស់ខ្លួនការពារជនខិលខូចលួចប្លន់ទ្រព្យសម្បត្តិប្រជាជន[៥] ។

## ខ.៤.ចំណុចប្រលោមនិយមក្នុងស្នាដៃ "កុលាបប៉ៃលិន"

យើងបាននិយាយពីខាងដើមថា ការសិក្សារឿងកុលាបប៉ៃលិនឈរលើកត្តាសង្គម ចិត្តសាស្ត្រខ្មែរ ហើយយោលតាមលក្ខណៈ សង្គមខ្មែរពិតប្រាកដ នោះយើងនឹងអាចឃើញចំណុច អណ្តែតអណ្តូងនៅក្នុងស្នាដៃនេះទោះបីក្នុងផ្នែកមុន យើងបាននិយាយពីចំណុចតថៈខ្លះៗ ហើយក៏ដោយ។ ជាការពិតណាស់ ដែលអ្នកនិពន្ធ បង្កើតតួអង្គចៅចិត្រពោរពេញដោយលក្ខណៈតថៈ តែជោគជ័យដ៏ធំធេងក្នុងឆាកជីវិតចៅចិត្រ បានធ្វើឲ្យយើងចាប់អារម្មណ៍ដល់ចំណុចអណ្តែតអណ្តូងក្នុងគំនិតអ្នកនិពន្ធ។ ក្នុងទីនេះ យើងអាចសិក្សាខ្លះៗពីសង្គមចិត្តសាស្ត្រខ្មែរ

---

[៥] សោម សុមុនី "វិភាគទានក្នុងការសិក្សាអក្សរសិល្ប៍ខ្មែរ" ទំព័រ១៣៣ ឆ្នាំ២០១៥

តាមកត្តាសត្យានុម័ត និងតាមស្នាដៃមួយចំនួនដទៃទៀត នោះយើងឃើញថា គំនិតលោក ញ៉ុក ថែម មានលក្ខណៈប្រលោមនិយម (Romantism) ឬស្រមើស្រមៃនិយម[៦] ។

ក្នុងសង្គមខ្មែរ គ្មានវណ្ណៈច្បាស់លាស់ទេ តែវាមានទំនាស់រវាងអ្នកមាន និងអ្នកក្រ។ បើទោះបីទំនាស់នេះវាមិនសូវស្រួចស្រាវដូចទំនាស់វណ្ណៈតាមទ្រឹស្តីម៉ាក់ស៊ីស ក៏វាជាបញ្ហាមួយដែលសង្គមយកចិត្តទុកដាក់។ អ្នកមាន អ្នកក្រ ជាស្រទាប់មនុស្សពីរប្រភេទក្នុងសង្គមខ្មែរ ហើយតែងតែមានទំនាស់នឹងគ្នា ដោយអ្នកមានមើលងាយអ្នកក្រ ព្រោះពួកគេគិតថា អ្នកក្រខ្ជិលហើយល្ងង់ ឯអ្នកក្រខ្លះច្រណែនអ្នកមាន ឯខ្លះស្អប់ ព្រោះត្រូវអ្នកមានមើលងាយតាមរយៈពាក្យសម្តី ឬកាយវិការ។

ដូចយើងបាននិយាយពីខាងដើមរួចមកហើយថា បញ្ហាមានក្រនេះត្រូវបានចោទឡើងស្ទើរតែក្នុងគ្រប់ស្នាដៃអក្សរសិល្ប៍ខ្មែរទាំងអស់។ អ្នកនិពន្ធភាគច្រើនៗ យកបញ្ហានេះ ជាបុព្វហេតុនៃទំនាស់ទាំងអស់ពិសេសបញ្ហានេះជាឧបសគ្គក្នុងរឿងស្នេហា។

នៅក្នុងសង្គមក៏ដូចជាក្នុងស្នាដៃ គេតែងពិចារណាលើបញ្ហាថា តើស្រទាប់ពីរនេះ អាចរលាយចូលគ្នាបានឬទេ?

អ្នកនិពន្ធមួយចំនួនបានតាក់តែងស្នាដៃ ដោយបង្ហាញឲ្យឃើញថាវណ្ណៈពីរនេះ មិនអាចរលាយចូលគ្នាបានទេ។ ឧទាហរណ៍ៈ រឿងទុំទាវ ដោយសារបញ្ហាទ្រព្យសម្បត្តិ ម្តាយទាវ ហ៊ានរហូតដល់បញ្ញាឲ្យគេសម្លាប់ទុំ ដែលស្តេច បានរៀបការឲ្យជាមួយទាវ ដែលជាកូនស្រីរបស់គាត់រួចទៅហើយ។ ឯតួអង្គធនញ្ជ័យក្នុងអក្សរសិល្ប៍ប្រជាប្រិយខ្មែរ មានទំនាស់ជាមួយសេដ្ឋីជាមួយស្តេចរហូតដល់ស្លាប់ ក៏នៅតែបន្តទំនាស់ទៀត។

លោក សរ សារុន បានសរសេរក្នុងសៀវភៅអត្ថាធិប្បាយទស្សនវិជ្ជារបស់គាត់ថា អ្នកមាន និងអ្នកក្រ ក្នុងសង្គមខ្មែរ មិនមែនជាវណ្ណៈដាច់ខាតទេ ព្រោះអ្នកមានអាចទៅជាអ្នកក្រ បើមិនធ្វើការ ហើយចាយវាយខ្ជះខ្ជាយឬអ្នកមានក៏អាចធ្លាក់ខ្លួនក្រដោយចៃដន្យ ឯអ្នកក្រអាចទៅជាអ្នកមាន បើខិតខំរកស៊ី។ គំនិតនេះបានបង្ហាញតាមរយៈអ្នកនិពន្ធខ្មែរមួយចំនួន។ ក្នុងរឿង "ជាតិស្ត្រី" របស់លោក ឡឹក វ៉ារី អ្នកនិពន្ធបានបង្ហាញពីរជោគជ័យរបស់នារីម្នាក់ ដែលបានតស៊ូព្យាយាមតាំងពីក្រីក្ររហូតដល់ក្លាយជាអ្នកមាន ហើយវិបត្តិស្នេហានាងដែលចោទឡើងកាលពីនាងនៅក្រីក្រ ក៏ត្រូវដោះស្រាយរួច ពេលដែលនាងក្លាយជាអ្នកមាន។ ឧទាហរណ៍ៈ នាងសំនៀង ត្រូវបានឃោធិន និងក្រុមគ្រួសារបដិសេធ មិនទទួលស្គាល់នាងជាប្រពន្ធ និងជាកូនប្រសារ ក្នុងគ្រាដែលនាងមានជីវភាពក្រក្រី...តែក្រោយមក នៅពេលដែលនាងរកស៊ីមានបាន រហូតក្លាយខ្លួនជាម្ចាស់ហាងកាត់ដេរសំលៀកបំពាក់ និងអ៊ុតសក់ សំនៀងថ្មី ស្រាប់តែប្តី និងក្រុមគ្រួសារ ជាពិសេសគឺអ្នកស្រីមន្ថា បានមកសូមទោសនិងទទួលស្គាល់កូនប្រសារ ឯឃោធិនវិញ ក៏បានគោរពតាមលក្ខ័ខ័ណ្ឌគ្រប់យ៉ាងរបស់នាងដែរ។ តែគំនិតនេះ ក៏មិនមែនជាការផ្សះផ្សាវណ្ណៈដែរ គឺគ្រាន់តែជាការប្រែក្លាយវណ្ណៈតែប៉ុណ្ណោះ។

យើងអាចនិយាយបានថា ស្នាដៃទាំងនោះ មានលក្ខណៈតថៈ ព្រោះវាស្របនឹងការពិតក្នុងសង្គមខ្មែរ។

ការពិតក្នុងសង្គមខ្មែរ សម័យលោក ញ៉ុក ថែម ការជិះជាន់មានកម្រិតខ្លាំងណាស់។ រដ្ឋអំណាចនៃប្រទេសកម្ពុជា នាពេលនោះគឺស្ថិតក្រោមអាណានិគមនិយមបារាំង។ អាណានិគមនិយមបារាំងក្តាប់អំណាចទាំងអស់ក្តាប់នយោបាយខ្មែរទាំងអស់ហើយក្រោមបារាំងផ្ទាល់ គឺមានពួកសក្តិភូមិគឺស្តេចខ្មែរ និងមន្ត្រីខ្មែរគ្រប់ជាន់ថ្នាក់ ដែលវាយឫក ដាក់ប្រជាជនដោយអាងលើជំហរផ្លូវការរបស់ខ្លួន ក៏បានរំលោភជិះជាន់ប្រជាជនតាមអំពើចិត្ត។ ចំណែក

[៦] វ៉ាន់ឌី កាអុន ប្រាកដនិយម និងអណ្តែតអណ្តូងនិយម បោះពុម្ពនៅគ្រឹះស្ថានមិត្តភាព ភ្នំពេញ ទំព័រ៤៨ ឆ្នាំ១៩៧៣

ពួកឈ្មួញ សេដ្ឋី ឬអ្នកមានទ្រព្យសម្បត្តិ ដែលចាត់តាំងគ្នាជាអនុភាពដ៏ច្បាស់លាស់ហើយនោះ ក៏ក្លាយជាអ្នកកណ្តាល រវាងអ្នកកាន់អំណាច និងប្រជាជន រួចហើយគេអាចយកអង្គការរដ្ឋធ្វើជាឧបករណ៍បម្រើផលប្រយោជន៍គេ គឺប្រយោជន៍ក្នុងការកេងប្រវ័ញ្ចពីប្រជាជនក្រីក្រ។ ឯប្រជាជនមហាជនស្ថិតនៅក្នុងក្តី លំបាកវេទនារាល់ថ្ងៃ ដោយបានរែកពុននូវបន្ទុកទាំងអស់របស់ពួកវណ្ណៈជិះជាន់ ។ ដូច្នេះ យើងអាចមើលឃើញយ៉ាងច្បាស់ នូវគម្លាតគ្នា រវាងពួកវណ្ណៈជិះជាន់និងប្រជាជន។

ឯក្នុងទំនាក់ទំនងស្នេហា បើកាលណាមានការឆ្លងវណ្ណៈនេះ គឺមិនដែលបានសុខទេ វណ្ណៈជាឧបសគ្គ ធំបំផុតក្នុងរឿងស្នេហា។ ជាទូទៅក្នុងបញ្ហានេះខ្មែរតែងនិយាយថា" ខ្លួនទាបកុំតោង ដៃខ្លីកុំឈោងស្រវាអោបភ្នំ " បានន័យថាបើខ្លួនក្រីក្រ ចូរកុំប្រាថ្នាអ្នកមាន។

និយាយរួមក្នុងសង្គមខ្មែរ គេមិនដែលឃើញមាន ការភ្ជាប់វង្សត្រកូលគ្នា រវាងវណ្ណៈទាំងពីរ បែបនេះ ឡើយ។ ធម្មតាស្តេចតែងរៀបការជាមួយស្តេច កូននាម៉ឺនធំៗ រៀបការជាមួយកូននាម៉ឺនធំៗ ឬជាមួយកូនពួកអ្នកមាន ឯកូនអ្នកក្រត្រូវរៀបការជាមួយកូនអ្នកក្រ។ កន្លងមក យើងឃើញអ្នកនិពន្ធមួយចំនួនធំ បានបង្ហាញពីតថភាពបែបនេះយ៉ាងពិតប្រាកដ។

អ្នកមានដែលបានរស់នៅក្នុងប្រណីតភាពក៏មិនមែនដោយសារគុណធម៌នេះដែរ តែដោយសារបាបធម៌ទៅវិញទេគឺ "ស្លូតស្លាប់ រៀចរេរមានក័ព្វអាយុយឺនយូរ"។ តាង៉ុយបានសរសេរថា "មួយទៀតទូជេន ធ្វើបាបបានបុណ្យ គឺបុណ្យមន្ត្រី ទោសទៅចង់ចាប់ កាប់ឥតប្រណី បានបុណ្យមន្ត្រីព្រោះបុណ្យធ្វើបាប"។

តួអង្គលោកហ្លួងរតនសម្បត្តិ គឺជាសេដ្ឋីដែលកាន់កាប់ត្បូងនៅប៉ៃលិនទាំងមូល បើនៅក្នុងសង្គមជាក់ស្តែងវិញ មនុស្សរបៀបនេះ មានអំណាចដូចស្តេចផែនដី ព្រោះនៅស្រុកខ្មែរ មានលុយគឺមានអំណាច។ ដូចនេះ ការដែលជននេះព្រមឲ្យកូនក្រមុំទៅចៅចិត្រ អាចថាជារឿងមួយដែលហួសពីការពិត។

អ្នកនិពន្ធ ញ៉ុក ថែម បានឲ្យតម្លៃខ្ពស់លើគុណធម៌បុគ្គល វាស្របនឹងគោលការណ៍សង្គមហើយ តែវាផ្ទុយពីសត្យានុម័ត។ យើងឃើញមានស្នាដៃអក្សរសិល្ប៍ប្រជាប្រិយមួយចំនួនក៏មានគំនិតរបៀបនេះដែរ តែនៅក្នុងរឿងព្រេងអ្នកនិពន្ធច្រើនបញ្ចូលការចៃដន្យគួបផ្សំនឹងគុណធម៌របស់តួអង្គ។ យើងអាចនិយាយថា មូលបញ្ហារឿងកុលាបប៉ៃលិនជាបញ្ហានៃសង្គមខ្មែរ តែក្នុងសម្រាយបញ្ហារបស់អ្នកនិពន្ធមិនស្របនឹងតថភាពឬសត្យានុម័តឡើយ។ ឯការសិក្សារបស់យើង ទោះបីវាផ្ទុយពីគោលការណ៍អប់រំ ដោយយើងគ្មានជំនឿលើគុណធម៌ តែវាស្របនឹងការពិតពិសេសគឺការពិតក្នុងសង្គមខ្មែរកន្លងមក[៧] ។

**សរុបមក**

ក្នុងការសិក្សាកន្លងមកឃើញថា ក្រៅពីការប្រើប្រាស់ពាក្យរាយក្នុងការតាក់តែងស្នាដៃអក្សរសិល្ប៍ ការឆ្លុះបញ្ចាំងពីតថភាពសង្គម គឺជាលក្ខណៈពិសេសមួយក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរ នាសម័យកាលរឿងកុលាប ប៉ៃលិន ខុសពីស្នាដៃអក្សរសិល្ប៍បុរាណ ដែលបង្ហាញតែរឿងរ៉ាវដែលទាក់ទងនឹងសាសនា រឿងកុលាបប៉ៃលិន បានឆ្លុះបញ្ចាំងយ៉ាងជ្រាលជ្រៅពីតថភាពក្នុងសង្គមខ្មែរក្នុងសម័យកាលមួយដែលអ្នកនិពន្ធបានរស់នៅ។ដំណើររឿងបានបង្ហាញឲ្យឃើញថា អ្នកនិពន្ធមានការយល់ដឹងច្រើនអំពីធម្មជាតិ និងសង្គមជាតិក្នុងប្រទេសរបស់ខ្លួន។ ស្នាដៃទាំងមូលបង្ហាញឲ្យយើងឃើញពីអ្វីដែលមានពិត ក្នុងប្រទេសកម្ពុជា ដូចជាឈ្មោះទីកន្លែង ធម្មជាតិ និងជីវភាពសង្គមនាសម័យនោះជាដើម។

---

[៧]តាន់ សុគន្ធា និក្ខេបបទថ្នាក់បណ្ឌិត "ចលនាប្រលោមលោកខ្មែរសម័យទំនើបពីឆ្នាំ១៩៣៨-១៩៧០ ទំព័រ១៤៣ ឆ្នាំ២០១១

ក្នុងការសិក្សាកន្លងមកយើងឃើញថា ក្នុងស្នាដៃនេះមានចំណុចប្រលោមនិយម ឬអណ្តែតអណ្តូងមែនតែ យើងយល់ថា នេះជាការធម្មតា ព្រោះវាមិនអាចមានតថភាពល្អឥតខ្ចោះនៅក្នុងស្នាដៃឡើយ។ ស្នាដៃរឿងរឿង កុលាបប៉ៃលិនអាចឲ្យឈ្មោះថា ខេមរនិយម ដែលលាតត្រដាងពីជីវភាពមួយ ក្នុងការស្រមៃរបស់អ្នកនិពន្ធ តែយើង មិននិយាយថា ការស្រមៃនោះមានលក្ខណៈប្រតិកិរិយាឡើយ ព្រោះជាការស្រមៃមួយឈានទៅរកអ្វីដែលល្អ។ យើងយល់ថាគំនិតផ្សះផ្សាវណ្ណៈ និងការឲ្យតម្លៃលើគុណធម៌របស់លោក ញ៉ុក ថែម ស្ថិតលើមូលដ្ឋានទ្រឹស្តីព្រះពុទ្ធ សាសនា ដែលនិយមដោះស្រាយបញ្ហាតាមសន្តិវិធី និងដែលតែងតែប្រៀនប្រដៅមនុស្ស ឲ្យជឿលើកុសលលើអំពើ ល្អ។ សន្និដ្ឋានបែបនេះ ព្រោះលោក ញ៉ុក ថែម ជាអ្នកបួសរៀនក្នុងព្រះពុទ្ធសាសនាចេះព្រះធម៌ យ៉ាងជ្រាលជ្រៅ ហើយក្នុងមជ្ឈដ្ឋានពុទ្ធសាសនិកជនក៏គេអប់រំដូច្នេះដែរថា " អ្នកមានក្បោខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញក្បាខ្លៅ ដូចសំពៅពឹងសំប៉ាន "។

យើងអាចសន្និដ្ឋាន លើគំនិតរបស់លោក ញ៉ុក ថែម តាមរយៈរឿងតំណាលមួយ ឬថាលោក ញ៉ុក ថែម បានជួបនឹងព្រឹត្តិការណ៍គួរឲ្យរន្ធត់មួយ ដោយមានយុវកម្មករម្នាក់ បានទាក់ទងស្រលាញ់គ្នាយ៉ាងស្វាត់កំបាំង ជាមួយកូនក្រមុំថៅកែម្នាក់នៅបាត់ដំបង។ ក្រោយមកថៅកែនោះបានដឹងក៏ជួលមនុស្សឲ្យទៅចាប់យុវជននោះវាយ ដំរហូតដល់បាត់បង់ជីវិត ។

លោក ញ៉ុក ថែម ឈឺចាប់ចំពោះអំពើព្រៃផ្សៃបែបនោះ លោកគិតថាមនុស្សមិនត្រូវធ្វើបាបមនុស្សឡើយ ទើបលោកនិពន្ធរឿងកុលាបប៉ៃលិននេះឡើង ក្នុងបំណងអប់រំមនុស្ស ឲ្យចេះស្រលាញ់គ្នាទោះមានក្តី ក្រក្តី ។ បើ យោងតាមរឿងដំណាលនេះ (មានន័យថា) **លោក ញ៉ុក ថែម មិនមែនយល់ថា ការពិតមានដូចក្នុងរឿងរបស់លោក ទេ តែលោកចង់ឲ្យមានការពិតដូចនេះ**។ ទស្សនៈផ្តើមចេញពីមូលដ្ឋានមនុស្សធម៌ មេត្តាធម៌ ចង់ឲ្យមានការមេត្តា ដល់មនុស្សដូចគ្នា ។ នេះជាទស្សនៈជឿនលឿន មិនមែនប្រតិកិរិយាឡើយ តែបើយើងពិនិត្យទៅលើលទ្ធភាពក្នុង ការផ្សះផ្សាវណ្ណៈរបស់លោក គឺតម្លៃការងារការសន្តោស និងសេចក្តីស្នេហា និងពិនិត្យលើការពិតក្នុងសង្គមនោះ យើងឃើញថា លោកញ៉ុក ថែម នៅតែជាអ្នកនិពន្ធស្រមើលស្រមៃ គ្រាន់តែការស្រមើស្រមៃនោះ គឺសុទិដ្ឋិនិយម ។

ទោះជាស្នាដៃរឿង " កុលាបប៉ៃលិន " នេះ មានចំណុចពិតខ្លះៗ ក៏ស្នាដៃនេះនៅតែជាស្នាដៃ ដែលប្រជា ជនខ្មែរនិយមចូលចិត្តយ៉ាងខ្លាំង យើងអាចនិយាយបានថា ប្រហែលជាប្រជាជនខ្មែរក៏ចូលចិត្តការស្រមើស្រមៃបែប នេះដែរ ព្រោះលោកធ្លាប់ស្រមៃតាមអក្សរសិល្ប៍ពុទ្ធនិយមរាប់សតវត្សមកហើយ។ ស្នាដៃនេះត្រូវបានគេយកទៅស ម្តែងជាល្ខោននិយាយ ហើយតួអង្គចៅចិត្រ និងយុននារី ក្លាយជាគំរូនៃការចំអន់លេងរបស់ យុវជនជំនាន់ក្រោយៗ ព្រោះកាលណា បើមានយុវជនដើរកាន់កន្ត្រក ទៅផ្សារជាមួយនារី គេថាយុវជននោះ ជាចៅចិត្រ ឯនារីនោះជាយុន នារី ហើយគេសើចចំអែចំអន់គ្នាលេង ព្រោះការនេះវាផ្ទុយពីទម្លាប់ខ្មែរពីមុនៗ ដែលនារីជាអ្នកយួរកន្ត្រកទៅផ្សារមិន មែនបុរសទេ។ តែនោះយ៉ាងណាក៏ភាពចំអែចំអន់បែបនេះបានក្លាយជាការគោរពសិទ្ធិ និងការឲ្យតម្លៃដល់ស្ត្រី ការងារមេផ្ទះរបស់ស្ត្រី សមស្របតាមសិទ្ធិមនុស្ស សមភាពយេនឌ័រ ក្នុងសង្គមបច្ចុប្បន្ននេះ។ ការលើកទឹកចិត្ត ការ ឲ្យតម្លៃ ការចែករំលែកការងារពីស្ត្រី ជាការបង្កើតសុខុមភាពក្នុងគ្រួសារ សង្គមជាតិ ហើយបុរសដែលមានស្មារតី បែបនោះ គេច្រើនហៅថា សុភាពបុរស និងជាស្វាមីល្អ(ឧត្តមស្វាមី) ដែលស្ត្រីទាំងឡាយប្រាថ្នា៕

# សិក្សារឿងផ្កាស្រពោន

## ក.ជីវប្រវត្តិអ្នកនិពន្ធ:

លោក **នូ ហាច** កើតនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩១៦ នៅឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្ត បាត់ដំបង។ ឪពុក នាម ឃួន នៅ និងម្តាយនាម ឱរ មួច ពួកគាត់ជាកសិករ។ លោក នូ ហាច ជាកូនច្បង និងមានប្អូនៗច្រើននាក់ទៀត ក្នុងនោះមានប្អូនស្រី៣នាក់ផងដែរ។កាលពីកុមារភាពលោកសិក្សានៅសាលាបឋមសិក្សាវត្តកំពង់ព្រះដែលមានគ្រូជាព្រះសង្ឃនៅសាលានេះហើយដែលលោកចេះអានសាស្ត្រាស្លឹករឹតយ៉ាងស្ទាត់ជំនាញ។ ឆ្នាំ១៩៣២ លោកបានប្រលងជាប់ ចូលរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ លោកតស៊ូរៀនសូត្ររហូតបានទទួលសញ្ញាប័ត្រកម្រិតមធ្យមសិក្សា។ បន្ទាប់ពីទទួលបានសញ្ញាបត្រនៅវិទ្យាល័យព្រះស៊ីសុវត្ថិ លោក នូ ហាច បានចេញទៅបំពេញការងារនៅខេត្តសៀមរាប ជាចៅក្រម។

- ឆ្នាំ១៩៤៧ លោកបានបានធ្វើការជាអ្នកបោះពុម្ពផ្សាយឱ្យកាសែតកម្ពុជា ក្នុង ក្រសួងព័ត៌មាន។
- ឆ្នាំ១៩៤៨ លោកបានក្លាយជាលេខាផ្ទាល់របស់នាយករដ្ឋមន្ត្រី( យុត្តិវង្ស)។ បន្ទាប់មក លោកបានវិលមកធ្វើការឱ្យក្រសួងព័ត៌មានវិញ មានឋានៈជា ប្រធាននាយកដ្ឋាន។
- ឆ្នាំ១៩៥២ លោកបានផ្លាស់ទៅធ្វើការនៅក្រសួងការបរទេស ជាប្រធានផ្នែកកិច្ចការ នយោបាយការបរទេស (Director en Direction des Affaires Politiques)។ ក្នុងការងារថ្មីនេះលោកត្រូវបានតែងតាំងឱ្យទៅបំពេញបេសកកម្មផ្សេងៗនៅបរទេសដូចជា ទៅប្រទេសសៀម និង យូហ្គោស្លាវីជាដើម។ ក្រោយមកដោយសារលោកមានស្នាដៃក្នុងការងាររាជរដ្ឋាភិបាលប្រចាំនៅប្រទេសឥណ្ឌូនេស៊ី ប្រទេសវៀតណាម និងជាអ្នកតំណាងពិសេសប្រចាំអង្គការសហប្រជាជាតិផងដែរ។
- ឆ្នាំ១៩៥២ នាយករដ្ឋមន្ត្រី សម្តេចព្រះនរោត្តមសីហនុ បានតែងតាំងលោកនូ ហាច ជារដ្ឋលេខាធិការក្រសួងសាធារណការ និងគមនាគមន៍ ដោយព្រះរាជក្រិត្យលេខ២៥២។
- ១៧ មករា ឆ្នាំ១៩៥៨ លោកបានចូលជាសមាជិកនៃសមាគមអ្នកនិពន្ធខ្មែរ( ទស្សនាវដ្តីអ្នកនិពន្ធខ្មែរ ឆ្នាំទី២ លេខ ៣ ខែកុម្ភៈ ឆ្នាំ១៩៩៦ ទំព័រ១៣) (សមាគមអ្នកនិពន្ធខ្មែរកើតនៅឆ្នាំ ១៩៥៤ ដោយលោករឹម គីន)។

លោក នូ ហាច ត្រូវបានគេទទួលស្គាល់ជាពិសេស ក្នុងស្នាដៃរឿងមនោសញ្ចេតនាដែលមានចំណងជើងថា ផ្កាស្រពោន។ តែជារួមលោកមានស្នាដៃផ្សេងៗទៀតដូចជារឿងខ្លី កំណាព្យ (លោកសរសេរកំណាព្យជាកាព្យបែបបារាំង)។ល។ លោកជាអ្នកនិពន្ធ ដែលសរសេរអោយទស្សនាវដ្តីរាត្រីថ្ងៃសៅរ៍ ទស្សនាវដ្តីនារី ទស្សនាវដ្តីរួមមិត្ត។ល។ ចំណងជើងអត្ថបទនានាដែលប្រមូលបានមាន៖

1. រឿងផ្កាស្រពោន ឆ្នាំ១៩៤៩
2. រឿងមាលាដួងចិត្ត ឆ្នាំ១៩៧២
3. រឿង ត្រួយជីវិត ឆ្នាំ១៩៧៣
4. មធុរសជាតិ សិក្សាអត្ថបទ ដកស្រង់ពីទស្សនាវដ្តីនារីលេខ១០ ទំព័រ៣៥៣ ដល់ ៣៥៦ ខែតុលា ឆ្នាំ១៩៥១
5. រឿងខ្លី កូនក្រក ផ្សាយដោយទស្សនាវដ្តីរួមមិត្តលេខ៨ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៥៣ ទំព័រ១៥ និង១៦។
6. ដំណើរចេញទៅប្រទេសបារាំង កាព្យបែបបារាំង ផ្សាយដោយទស្សនាវដ្តីនារី លេខ១៥ ឆ្នាំ ១៩៥២។

7. ខ្ទីង កាព្យបែបបារាំង ផ្សាយដោយទស្សនាវដ្ដីនារីលេខ ១១ ខែវិច្ឆិកា ឆ្នាំ១៩៥១ ទំព័រ៣៩៦។
8. រឿង នារីជាទីស្នេហា ឆ្នាំ១៩៥៣
9. លាវណ្យ និង វរិន្ទ ឆ្នាំ១៩៥៣ បោះពុម្ពភាគ១ ឆ្នាំ ១៩៥៥ បោះពុម្ពភាគ២
10. រឿងខ្លី ល្បាតគយក្នុងគ្រាមួយនៅទន្លេសាប ដកស្រង់ពីទស្សនាវដ្ដីរាត្រីថ្ងៃសៅរ៍ លេខ ១០ ថ្ងៃ ទី១៩ ខែកុម្ភៈ ឆ្នាំ ១៩៥២ ទំព័រ២៩ ដល់៣១។
11. ថូបែក កាព្យបែបបារាំង លោកនូ ហាចដកស្រង់ពីទស្សនាវដ្ដីនារីលេខ១៣ ខែមករា ឆ្នាំ ១៩៥២ ទំព័រ១១។

លោក នូ ហាច បានរៀបការជាមួយអ្នកស្រី តាន់ រ៉េម និងមានបុត្រចំនួន៨នាក់។ សព្វថ្ងៃកូនៗ របស់លោកមួយចំនួនរស់នៅសហរដ្ឋអាមេរិក និងអូស្ត្រាលី។ ចុងក្រោយ ប្រហែលនៅឆ្នាំ១៩៧៥ គេសន្និដ្ឋានថា លោកអាចត្រូវបានពួកខ្មែរក្រហមសំលាប់[៨]។

## ខ.សង្ខេបរឿង ផ្កាស្រពោន:

ប៊ុនធឿន និងវិធាវី ជាគូដណ្ដឹងនឹងគ្នាតាំងពីតូចមក ហើយគ្រួសារយុវជនទាំងពីរនេះធ្លាប់បានស្រឡាញ់រាប់អានគ្នាណាស់។ គ្រួសារប៊ុនធឿនមានបួននាក់គឺ ឪពុកឈ្មោះ ប៊ុនថន ម្ដាយឈ្មោះ ង៉ាន់ ប្អូនស្រីឈ្មោះ សោភ័ណ និងប៊ុនធឿន។ ពីមុនគ្រួសារនេះ ជាអ្នកមានទ្រព្យសម្បត្តិធូរធារ នៅភូមិកំពង់ព្រះ ជិតក្រុងបាត់ដំបង តែក្រោយមក នៅពេលដែលប៊ុនធឿនកំពុងបន្តការសិក្សានៅភ្នំពេញ គ្រួសារនេះបានធ្លាក់ខ្លួនក្រយ៉ាងខ្លាំង ដោយឪពុកប៊ុនធឿនមានគ្រោះថ្នាក់លិចទូកដឹកទំនិញ។ នៅពេលវ៉ាកងធំ ប៊ុនធឿន បានត្រឡប់មកស្រុកកំណើតវិញរួចជួយធ្វើស្រែឪពុកម្ដាយ។ ដោយឃើញស្ថានភាពលំបាក ប៊ុនធឿនមានបំណងលះបង់ការសិក្សាដើម្បីជួយធ្វើការ តែឪពុកអ្នកជំទាស់។

ឯនាងវិធាវី ក្រោយពេលឪពុកស្លាប់ចោលទៅ នាងរស់នៅជាមួយម្ដាយឈ្មោះយាយនួន និងស្ត្រីចំណាស់បម្រើក្នុងផ្ទះឈ្មោះយាយផៃ។ វិធាវីមិនបានរៀនសូត្រជ្រៅជ្រះនៅសាលាទេ នាងគ្រាន់តែចេះអានភាសាខ្មែរ ភាសាថៃនិងវិជ្ជាដេរប៉ាក់។ នាងជានារីសុភាពស្លូតបូត និងមានសម្លេងពីរោះ។ ជារៀងរាល់រាត្រី នាងវិធាវីតែងអានសាស្ត្រាឱ្យម្ដាយនាងនិងម៉ែផៃស្ដាប់។ រាត្រីមួយ ម្ដាយនាងបាននិយាយប្រាប់នាង ពីការធ្លាក់ខ្លួនក្ររបស់គ្រួសារប៊ុនធឿន និងពីការផ្លាស់ប្ដូរចិត្តគំនិតរបស់គាត់ ដោយមិនចង់ឱ្យនាងរៀបការជាមួយប៊ុនធឿនតាមពាក្យសន្យាទេ។ រឿងនេះបានធ្វើឱ្យនាងកើតទុក្ខយ៉ាងខ្លាំង នាងនៅស្រលាញ់ប៊ុនធឿន តែនាងមិនហ៊ានជំទាស់នឹងបំណងម្ដាយឡើយ។

ថ្ងៃមួយ ជាថ្ងៃអាទិត្យ ប៊ុនធឿនបានទៅលេងបុណ្យ ហើយបានឆៀងចូលទៅលេងផ្ទះវិធាវី។ ពេលនោះវិធាវីនៅផ្ទះតែម្នាក់ឯង ប៊ុនធឿនរីករាយណាស់ តែនាងបែរជាបង្ហាញពីការព្រួយបារម្ភពីអនាគតនៃសេចក្ដីស្នេហា រួចហើយនាងក៏ប្រគល់រូបថតមួយសន្លឹកឱ្យប៊ុនធឿន។ អ្នកទាំងពីរមិននៅជួបមុខគ្នាយូរទេ ព្រោះវិធាវីខ្លាចពាក្យនិន្ទា ប៊ុនធឿន ក៏បានឃ្លាតពីនាងវិធាវីដោយមិនដឹងថា នាងត្រូវម្ដាយបង្ខំឱ្យបំភ្លេចខ្លួនឡើយ។

ពេលដែលយាយនួនកំពុងរកលេសផ្ដាច់ពាក្យនាងវិធាវី ពីប៊ុនធឿន ដើម្បីឱ្យអ្នកដទៃចូលដណ្ដឹង យាយចាន់ ជាមិត្តរបស់គាត់បានមកនិយាយប្រាប់ថា ថៅកែណៃស៊ាន និងនាងថូជាប្រពន្ធ ចង់ស្ដីដណ្ដឹងវិធាវី ឱ្យកូនប្រុសខ្លួនឈ្មោះណៃស៊ត។ យាយនួនត្រេកអរខ្លាំងណាស់ ក៏បានសួរខែឆ្នាំកំណើតណៃស៊តនោះ ហើយទៅរកគ្រូទាយពីការផ្សំផ្គុំ ណៃស៊តនោះជាមួយនឹងកូនស្រីគាត់។ ពេលទស្សន៍ទាយឃើញថាល្អហើយ គាត់ក៏ទៅប្រាប់យាយ

---

[៨] https://km.wikipedia.org/wiki/នូ_ហាច

ចាន់ភ្លាមថា គាត់យល់ព្រម។ ប៉ុន្មានថ្ងៃក្រោយមកយាយចាន់ ក៏បាននាំនាងថូ និងស្រីម្នាក់ទៀតឈ្មោះនាងធិន មកចូលស្តីដណ្តឹងនាងវិធាវី។ យាយនួនមិនបានទាំងសួរចិត្តកូនស្រីគាត់ឡើយ គាត់ក៏ព្រមលើកនាងវិធាវីឱ្យទៅគេ ដោយមិនដឹងថា ណៃស៊ិតនោះជាមនុស្សប្រភេទណាផង។ ចំណែកនាងវិធាវី គឺនៅតែស្រលាញ់ប៊ុនធឿន ដដែល ហើយនាងស្អប់ណៃស៊ិតនោះ ព្រមទាំងស្អប់ស្ត្រីទាំងអស់ ដែលមកចូលស្តីដណ្តឹងនាង តែនាងមិនបាននិយាយស្តីអ្វីទាំងអស់ជាមួយម្តាយនាងឡើយ។

វិធាវីបានសរសេរសំបុត្រប្រាប់រឿងទាំងនេះ ដល់ប៊ុនធឿន ដែលកំពុងរៀននៅឯភ្នំពេញដោយបញ្ជាក់ថា នាងនៅតែស្រលាញ់ប៊ុនធឿនដដែល និងមិនព្រមរៀបការជាមួយណៃស៊ិត ជាដាច់ខាត។ ប៊ុនធឿនបានសរសេរសំបុត្រតបវិញ ដោយទូន្មាននាងឱ្យស្តាប់តាមបង្គាប់ម្តាយ រួចហើយសុំរាប់អានគ្នាដូចបងប្អូនបង្កើតវិញ។

នាងវិធាវី បានចុះស្គមស្លេកស្លាំងដោយសេចក្តីទុក្ខព្រួយជាអនេក។ នាងចង់និយាយប្រាប់ម្តាយអំពី សេចក្តីស្នេហារបស់នាងចំពោះប៊ុនធឿន និងពីការមិនពេញចិត្តចំពោះគូរដណ្តឹងថ្មី ដែលជាមនុស្សពាល ធ្វើបាបនារីៗជាច្រើនមកហើយ តែនាងមានសេចក្តីអៀនខ្មាស និងមានទម្លាប់មិនឈ្លោះប្រកែកនឹងម្តាយ ទើបនាងសុខចិត្តនៅក្រៀមក្រំសំងំៗតែម្នាក់ឯង។ យាយនួនមិនបានដឹងពីទឹកចិត្តរបស់កូនស្រីគាត់ឡើយ ផ្ទុយទៅវិញគាត់សប្បាយរីករាយ ដោយបានជន្លងជាអ្នកមានទ្រព្យសម្បត្តិច្រើន។ គាត់និយាយថា ក្រោយពេលរៀបការរួច នាងវិធាវី នឹងបានសប្បាយរីករាយ រួចមានសុខភាពល្អ ឡើងវិញ។

ដោយឃើញកូនស្រីខ្លួនចេះតែស្រពោនទៅៗជាលំដាប់ យាយនួនក៏នាំនាងទៅលេងសៀមរាប-អង្គរ ដែលជារមណីដ្ឋានប្រកបដោយប្រាសាទបុរាណល្អវិចិត្រ និងមានធម្មជាតិគួរជាទីមនោរម្យ។ ពេលរៀបចេញដំណើរ គាត់បានជួបនាងថូ នាងថូជានាជូនដំណើរ តែនាងវិធាវីបដិសេធ។ នៅសៀមរាប យាយនួនបានសំណាក់នឹងគ្រួសារមិត្តភ័ក្តរបស់ខ្មោចប្តីគាត់។ នាងសុចិត្រា ជាប្រពន្ធម្ចាស់ផ្ទះពេញចិត្តនឹងវិធាវីណាស់។ អាកាសធាតុបរិសុទ្ធនៅសៀមរាប បានជួយវិធាវីឱ្យបានស្រួលក្នុងខ្លួន និងលុបបំបាត់អស់កង្វល់ខ្លះៗ។ លុះព្រឹកឡើងគេបានជិះរទេះសេះទៅលេងប្រាសាទអង្គរ។ នាងវិធាវីបានបន់ព្រះនៅទីនោះសូមឱ្យព្រះជួយនាង ឱ្យបានជួបប៊ុនធឿន។ ពេលនោះនាងថូ និងណៃស៊ិតជាកូន ក៏បានទៅដល់ទីនោះដែរ ហើយបបួលយាយនួន នាងវិធាវី ព្រមទាំងនាងសុចិត្រាឱ្យជិះរថយន្តវិញ។ នាងវិធាវីខឹងយ៉ាងខ្លាំង រួចនាងក៏ទាម្តាយសុំត្រឡប់មកសៀមរាបវិញភ្លាម។ តាមផ្លូវភ្លៀងធ្លាក់យ៉ាងខ្លាំង ធ្វើឱ្យនាងវិធាវីចាប់គ្រុនក្តៅរងាជាខ្លាំង ដោយការធ្វើដំណើរទាំងភ្លៀង។

លុះនាងវិធាវីបានធូរស្រាលហើយ ម្តាយនាងក៏នាំនាងមកបាត់ដំបងវិញ។ នាងវិធាវីនៅតែមានទុក្ខព្រួយដោយនឹកប៊ុនធឿនយ៉ាងខ្លាំង តែនាងមិនហ៊ានប្រាប់ម្តាយទេ ព្រោះនាងគិតដល់ប្រពៃណីខ្មែរ ដែលមិនអនុញ្ញាតឱ្យកូនស្រីរើសគូស្រករដោយខ្លួនឯង។ យាយនួនឃើញកូនចេះតែស្លេកស្លាំងទៅៗ គាត់គិតថា បើបានរៀបការឆាប់ៗប្រហែលជាល្អ ក៏ទៅពិគ្រោះជាមួយនាងថូ។ ពេលដែលឃើញគេរៀបចំកន្លែងសម្រាប់អាពាហ៍ពិពាហ៍ នាងវិធាវីកាន់តែឈឺខ្លាំងរហូតដល់ក្អួតធ្លាក់ឈាម ហើយដួលសន្លប់បាត់ស្មារតី។ គេបានអញ្ជើញទាំងពេទ្យសម័យ ទាំងគ្រូមន្តអាគម មកព្យាបាលវិធាវី តែជំងឺនាង នៅតែមានអាការៈធ្ងន់ធ្ងរដដែល ហើយនាងនៅតែមិនប្រាប់ម្តាយពីទឹកចិត្តស្នេហារបស់ខ្លួនចំពោះប៊ុនធឿនឡើយ។

រដូវប្រាំង ប៊ុនធឿនមកលេងស្រុកមួយខែ។ គេបានឮដំណឹងថា វិធាវីជិតរៀបការ គេមានសេចក្តីទុក្ខព្រួយជាខ្លាំង តែខំកាត់ចិត្ត ព្រោះគិតថា រូបគេ មិនអាចផ្តល់សុភមង្គលដល់នាងបានទេ។ ប៊ុនធឿនបានទៅព្រៃនាម

មាត់ទន្លេសាបជាមួយបងប្អូនប្រជាជនក្នុងភូមិដើម្បីរកចាប់សត្វ និងរកត្រីមកទុកធ្វើម្ហូប។ គេបានស្គាល់ធម្មជាតិប្លែកៗ និងព្រឹត្តិការណ៍ផ្សេងៗ ដែលក្នុងជីវភាពជាសិស្ស គេមិនដែលជួបប្រទះទាល់តែសោះ។

ល្ងាចមួយ ពេលជិះរ៉ឺម៉កកាត់តាមវត្ត ប៊ុនធឿនឃើញទង់ក្រពើពណ៌ស ប៊ុនធឿនមានអារម្មណ៍ចម្លែកក្នុងចិត្ត ក៏ចូលមើលកន្លែងតម្កល់សព។ ប៊ុនធឿនឃើញរូបថតវិធាវី។ នាងស្លាប់ ដោយមិនបានជួបមុខប៊ុនធឿនជាចុងក្រោយទេ។ ប៊ុនធឿនតក់ស្លុតជាខ្លាំង ពេលនោះម៉ែផៃ បាននាំប៊ុនធឿនទៅជួបយាយនួន ដែលមានរូបរាងស្គមស្លឹតស្លាំងខ្លាំងនោះ គាត់បានប្រគល់សំបុត្រ និងចិញ្ចៀនមួយវង់ ដែលវិធាវីបានផ្ញើទុកឱ្យប៊ុនធឿនមុនពេលនាងស្លាប់។ ប៊ុនធឿន អានសំបុត្រដែលវិធាវី បានបញ្ជាក់ពីសេចក្ដីស្នេហារបស់នាងចំពោះប៊ុនធឿន។ ប៊ុនធឿន អានសំបុត្រដោយទឹកភ្នែកហូរសស្រាក់។

## **គ.តម្លៃតថសង្គមក្នុងរឿងផ្កាស្រពោនៈ**

ការបញ្ចប់រឿងត្រឹមមរណភាពវិធាវីគឺជាការបញ្ចប់ដោយយោល ទាំងស្រុងតាមលក្ខខណ្ឌសត្យានុម័តសង្គមបរិយាកាស ពោលគឺលោកនូហាច ពុំបានបង្ហាញដំណោះស្រាយណាមួយតាមអត្តនោម័ត ដើម្បីបន្ធូរបន្ថយភាពនោះឡើយ។ ក្នុងការតែងនិពន្ធ លោកគ្រាន់តែបង្ហាញពីលក្ខខណ្ឌតែប៉ុណ្ណោះ។ បើសិក្សាលក្ខខណ្ឌទាំងពីរនោះ យើងឃើញថាវាសុទ្ធសឹងជាកត្តាបង្កឲ្យមានសោកនាដកម្មក្នុងរឿងផ្កាស្រពៀន រួចតម្លៃតថៈនៃស្នាដៃនោះ វាលេចឡើងតាម រយៈលោកនាកដម្មតាមលក្ខខណ្ឌសត្យានុម័តនោះឯង។

### **១. លក្ខខណ្ឌសង្គម**

ក្នុងការបកស្រាយពីជីវភាពក្នុងរឿងផ្កាស្រពោន លោកនូ ហាច បានបង្ហាញឲ្យយើងឃើញលក្ខណៈខុសឆ្គងទាំងក្នុងនិន្នាការក្នុងជីវភាពសង្គមខ្មែរ ដែលអាចចាត់ទុកថា ជាបុព្វហេតុសំខាន់ក្នុងវិបត្តិស្នេហាយុវជន។ តាមដំណើររឿង យើងសង្កេតឃើញថា អ្នកនិពន្ធហាក់ដូចជាសង្កត់ធ្ងន់លើនិន្នាការពីរៈគឺការនិយមទ្រព្យសម្បត្តិ និងការនិយមបំបាត់សិទ្ធិសេរីភាពយុវជនក្នុងការជ្រើសរើសគូស្រករ។ ដោយសានិន្នាការទាំងពីរនេះតួអង្គទាំងអស់ហាក់ដូចជាមានតែគុណវិបត្តិ ដែលសុទ្ធសឹងជា មូលហេតុកំណត់វាសនាអាក្រក់ដល់នាង វិធាវី។

ចំពោះនិន្នាការទីមួយ គឺទ្រព្យសម្បត្តិនិយម យើងអាចរកឃើញ ស្ទើរតែក្នុងគ្រប់ការបង្ហាញតួអង្គចឹកប៊ុនថន ជាឪពុក ប៊ុនធឿន យើងឃើញថាការខាតបង់ទ្រព្យ អាចធ្វើឲ្យមនុស្សបាត់បង់ទឹកចិត្ត ធ្លាក់ទឹកចិត្ត ទន់ជ្រាយ និងខ្វាយខ្វល់យ៉ាងខ្លាំង។ អំពីរឿងនេះ លោកនូ ហាច បានសរសេរថា "...ពីដើមមកគាត់បានខ្នះខ្នែងម៉ឺងម៉ាត់ក្នុងការរិជ្ជាជីវៈណាស់ ។ ឥឡូវសេចក្ដីទុក្ខព្រួយធ្វើឲ្យគាត់ទន់ដៃទន់ជើងនឹងធ្វើការអ្វីពុំកើត"។ គួរកត់សម្គាល់ថា ទុក្ខព្រួយរបស់ ចឹកប៊ុនថន ពេលនោះគឺបណ្ដាលមកពីការខាតបង់យ៉ាងធំក្នុងមុខជំនួញ។

-រូបាម្មណ៍ប៊ុនធឿន បានបង្ហាញថា ដោយសារតែ ការខ្វល់ខ្វាយ នឹងភាពតោកយ៉ាកក្នុងគ្រួសារ យុវជនប៊ុនធឿនអាចនឹងលះបង់ការសិក្សា រហូតដល់លះបង់គូសង្សារ។ តាមរយៈការសន្ទនារវាងចឹកប៊ុនថន និងកូនប្រុសគាត់ យើងដឹងថា ប៊ុនធឿនមានបំណងលះបង់ការសិក្សា មកជួយធ្វើការឪពុកម្ដាយ ។ រួចតាមរយៈសំបុត្រប៊ុនធឿនផ្ញើដល់វិធាវី ថាគេព្រមលះបង់នាង ព្រោះប៊ុនធឿន យល់ថាខ្លួនគេក្រមិនអាចផ្ដល់សុភមង្គលឲ្យនាង បាន" [...បងធ្លាក់ក្រហើយ...ណែស៊ិត ដល់គេចាស់ដៃ ចាស់ជើងទៅមុខ ជាបានជាពាណិជ្ជករយ៉ាងធំនៅប្រទេសកម្ពុជា... ចំណេះគេ ក៏មាន ទ្រព្យសម្បត្តិគេ ក៏មាន ដែលជាលក្ខណៈមួយអាចនាំអូនឲ្យបាន សុខសំរាន្ត ទៅថ្ងៃក្រោយ...]។ តាំងពីពេលនោះមកគេបំភ្លេចនាងវិធាវីឈឹងរហូតមិនដឹងថានាងស្លាប់ទៀតផង។

-ម្យ៉ាងវិញទៀតក៏ដោយសារការនិយមទ្រព្យសម្បត្តិនេះដែរ ដែលនាំឲ្យយាយនួនក្បត់ពាក្យសច្ចៈ ជាមួយគ្រួសារប៊ុនធឿន រហូតផ្ដាច់វិធាវីពីប៊ុនធឿន រួចលើកនាងឲ្យណៃស៊ត។ ដោយការសម្រេចនោះ នាងវិធាវី បានព្រាត់ពី ប៊ុនធឿន ជាហេតុធ្វើឱ្យនាងរងទុក្ខព្រួយរហូតដល់ស្លាប់។

ឯនិន្នាការទីពីរ គឺការរំលោភសិទ្ធិកូនក្នុងការកសាងគ្រួសារក៏ត្រូវបានលាតត្រដាងតាមរយៈយាយនួននេះដែរ។ តាមការបង្ហាញរបស់អ្នកនិពន្ធយើងឃើញថា យាយនួនមិនត្រឹមតែមិនសួរយោបល់កូនប៉ុណ្ណោះទេ តែថែមទាំងលាក់មិនឲ្យដឹងពីដំណើរការរៀបចំគ្រួសារជាមួយគូស្រករថ្មីនោះផង។ ឧទាហរណ៍ៈ ពេលយាយចាន់ ឬនាងថូមកទាក់ទងបញ្ហានោះ គាត់តែងតែរកលេសដេញនាងវិធាវីចេញពីបន្ទប់ មិនឲ្យការស្តាប់ការសន្ទនា។ រហូតដល់មានការព្រមព្រៀងទាំងសងខាងហើយ ទើបគាត់បង្ខំចិត្តកូនស្រីឲ្យព្រមតាមការសម្រេចរបស់គាត់តែម្តង។

ក្រៅពីនិន្នាការទាំងពីរខាងលើ ជីវភាពសង្គមពិសេសជីវភាពខាងស្មារតី គឺវិស័យជំនឿប្រជាជនក៏អាចចាត់ទុកថា ជាលក្ខខ័ណ្ឌអាក្រក់នៃសង្គមខ្មែរ សម្រាប់វាសនានាងវិធាវីដែរ។ ក្នុងដំណើររឿង អ្នកនិពន្ធបានបង្ហាញឲ្យយើងឃើញថា ប្រជាជនខ្មែរលុះលង់ក្នុងជំនឿមិនសមហេតុផល បីយ៉ាងគឺ ការជឿលើហោរាសាស្ត្រ ជំនឿលើសិល្ប៍សាស្ត្រ និងការជឿលើអារក្សអ្នកតា។ ក្នុងបញ្ហានេះ យើងសម្គាល់ឃើញថា អ្នកនិពន្ធមិនត្រឹមតែបកស្រាយតថភាពប៉ុណ្ណោះទេ តែថែមទាំងរិះគន់តថភាពសង្គមសម័យនោះទៀតផង។

ឧទាហរណ៍ៈ

-អំពីជំនឿលើក្បួនហោរាៈ ក្រោយពី លោកគ្រូអាន ភិក្ខុសង្ឃដែលមាននាមល្បីខាងហោរាសាស្ត្រ និង មន្តអាគមស្តោះព្រួសនៅវត្តពោធិវាល បានទស្សន៍ទាយឃើញថា ជោគជតានាងវិធាវី នឹងល្អប្រសើរក្រោយពេលរៀបការជាមួយណៃស៊ត នោះអ្នកនិពន្ធបានសរសេរថា" ឱព្រះភិក្ខុអើយ! ទំនាយក្បួនតម្រា និងពាក្យអធិប្បាយតាមគម្ពីររបស់លោកដែលជាអ្នកទ្រទ្រង់ព្រះពុទ្ធសាសនានៃព្រះបរមគ្រូនោះ បែរជានាំជនពីរនាក់ ដែលមាន សេចក្តីស្នេហាទៅវិញទៅមកយ៉ាងធំបំផុត ឲ្យខានបានជួបគ្នាទៅវិញ ហាក់ដូចជាលោកជួយប្រានគូសង្សារនេះទម្លាក់ទៅរណ្តៅទុក្ខសោកសង្រេង"។ បានន័យថា យាយនួនជឿហោរាណាស់ ដូចនេះ បើលោកគ្រូអានទាយថា វាសនានាងវិធាវី និងណៃស៊តមិនល្អនោះ គាត់ក៏មិនលើកវិធាវី ឲ្យណៃស៊តនោះដែរ រួចហើយនាងវិធាវីក៏មិនជួបវាសនា ដូច្នោះទេ ព្រោះការដែលនាងកើតទុក្ខយ៉ាងខ្លាំងរហូតដល់ស្លាប់នោះ ទីមួយ គឺដោយសារនាងស្រលាញ់ ប៊ុនធឿនពេក តែទីពីរ ដោយនាងស្អប់ណៃស៊ត យ៉ាងខ្លាំងមិនអាចអត់អោនបាន។ តែនេះលោកទាយថា "ល្អ" ធ្វើឲ្យយាយនួនកាន់តែជឿជាក់លើការសម្រេចលើកនាងវិធាវីឲ្យណៃស៊ត រហូតដល់មើលមិនឃើញ ស្តាប់មិនឮថាកូនគាត់ស៊ូស្លាប់ដោយមិនព្រមប្រគល់វាសនាដល់បុរសនោះដាច់ខាត។ ដូចនេះ តាមទស្សនៈលោកនូ ហាច ភិក្ខុ ដែលអនុវត្តហោរាស្ត្រនោះក៏បានរួមចំណែកបង្កសោកនាដកម្មក្នុងរឿងនោះដែរ។

-រួចមកទៀត ពេលនាងវិធាវីចាប់មានជំងឺ នោះគឺជំនឿលើសិល្ប៍សាស្ត្រ និងអារក្សអ្នកតា ដែលជាអ្នកបញ្ចប់ជីវិតនាង។ ក្នុងពេលឈឺធ្ងន់ដូចនោះ បើគេមិនជឿលើការព្យាបាលរបស់អ្នកសិល្ប៍សាស្ត្រ ឬគ្រូអារក្សទេ រួចគេអញ្ជើញគ្រូពេទ្យមកព្យាបាលតាមបែបវេជ្ជសាស្ត្រនោះប្រហែលជាអាចជួយជីវិតនាងវិធាវីបាន។ តែនេះគេមិនរវល់នឹងស្វែងយល់ពីប្រភេទជម្ងឺផង គឺគេគិតតែអញ្ជើញគ្រូមន្តអាគមទាំងនោះមកព្យាបាល ដែលតាមការបង្ហាញរបស់លោកនូហាច យើងឃើញដូចគ្រាន់តែជាអំពើល្ងិតល្ងង់ ឬឆ្កួតលីលាតែប៉ុណ្ណោះ ពោលគឺ គ្មានឃើញមានលក្ខណៈវេជ្ជសាស្ត្រឡើយ។ ឧទាហរណ៍ : ព្យាបាលរបស់គ្រូសិល្ប៍សាស្ត្រនោះ គឺអុជទៀនមក កូរទឹកលាយផ្កាម្លិះ ទន្ទឹមនឹងការសូត្រមន្តអាគម រួចយកមកស្រោចលើអ្នកជម្ងឺ ដែលកំពុងគ្រុនរងានោះ។ ត្រង់នេះក៏អ្នកនិពន្ធបានបញ្ចេញយោបល់ផ្ទាល់ខ្លួនរិះគន់ដែរ...។ អ្នកផងតែងដឹងថា ជម្ងឺពុកទ្រូងនេះ តាមនិយមវិទ្យាសាស្ត្រក្នុង

បច្ចុប្បន្នកាលគេត្រូវតែហ៊ុំដណ្តប់ឲ្យជិតមិនឲ្យត្រូវអាកាសធាតុត្រជាក់ ឬទឹកត្រជាក់សោះឡើយ។ ឥឡូវនេះ លោកដែលជាបព្វជិត មានសីល មានធម៌មកស្រោចទឹក បណ្តាលឲ្យជម្ងឺរោគនោះរឹតតែធ្ងន់ជាងមុនទៅទៀត។ ក្រោយមកអំពើគ្រូអារក្ស លោកនូ ហាច ចាប់ផ្តើមរិះគន់ តាំងពីពេលលោកធ្វើការពិពណ៌នារូបរាងតួអង្គនោះតែម្តង...។ ភ្ញៀវថ្មីនេះមានភ្នែកបាយម្ខាង ស្រលៀងម្ខាង អុតស៊ីសុសមុខ សក់ក្រញាញ់កន្ទ្រើងស្លៀកចងក្បិន និងពានាក្រមាមួយជាប់ក្អែលឡើងពញ្លាក់ ដែលអ្នកផងមិនអាចថាពណ៌នាអ្វីបានឡើយ។ ទីបំផុតលោក នូ ហាច សរសេរថា " ពាក្យសន្យាលោកគ្រូអាន និងមេមត់ព្រមទាំងឫទ្ធានុភាពនៃមន្តអាគម លោកភ្នំសំពៅក៏មិនឃើញជាបានផលប្រយោជន៍ឯណា នាងវិធាវីក៏នៅតែ ស្ដូកស្ដឹង...”។

សរុបមក បើនាងវិធាវី មិនរស់ក្នុងសង្គមបែបនោះទេ ប្រហែលនាងក៏មិនជួបស្ថានភាពធ្ងន់ធ្ងរយ៉ាងនោះដែរ តែនេះយើងឃើញថា គ្រប់លក្ខខ័ណ្ឌជីវិត ក្នុងសង្គមអាណានិគមបារាំងមិនឲ្យនាងបានសម្រេចសមដូចប្រាថ្នា មិនតែប៉ុណ្ណោះ វាជំរុញជីវិតនាងឲ្យជួបនូវមហន្តរាយថែមទៀត ។ ក្នុងសង្គមខ្មែរ មិនមែនមានតែ នាងវិធាវីម្នាក់ទេ ដែលព្រាត់ប្រាស់គូសង្សារ ដោយនិន្នាការទ្រព្យសម្បត្តិនិយម និងទស្សនៈនំមិនធំជាងនាឡិ បែបនេះ គឺនៅមានជាច្រើនទៀតដែរ ដែលស្លាប់ដោយសារជឿលើមន្តអាគម ជាងជំនឿលើវេជ្ជសាស្ត្រ។ ដូចនេះយើងឃើញថា បុព្វហេតុទីមួយ ដែលកំណត់សោកនាដកម្ម ផ្កាស្រពោន គឺបុព្វហេតុសង្គម រួចបើយើងពិនិត្យលើលក្ខខណ្ឌជីវភាពនាងផ្ទាល់ នោះយើងនឹងឃើញថា ទំនាក់ទំនងជីវភាពក្នុងគ្រួសារនាងរាល់ថ្ងៃ ក៏ជាបុព្វហេតុសំខាន់មួយដែរ ។

**២- លក្ខខណ្ឌជីវភាពវិធាវី:**

ជាការពិតណាស់ដែលថា ជីវភាពសង្គមវាមានឥទ្ធិពលដល់ដំណើរជីវិតបុគ្គល តែទន្ទឹមនឹងនេះ កត្តាគ្រួសារនិងកត្តាបុគ្គលផ្ទាល់ ក៏ជាកត្តាសំខាន់ក្នុងការកំណត់វាសនាមនុស្សដែរ។ ក្នុងរឿងផ្កាស្រពោនយើងមិនឃើញអ្នកនិពន្ធ រិះគន់ប្រការនេះទេ តែលោកបានបង្ហាញច្បាស់លាស់អំពីបុគ្គលិកលក្ខណៈរបស់វិធាវី ដែលតាមការសិក្សារបស់យើង យើងយល់ថានោះ ក៏ជាកត្តាកំណត់វាសនាអាក្រក់របស់នាងដែរ។

អំពីបុគ្គលិកលក្ខណៈវិធាវី លោក នូ ហាច បង្ហាញឲ្យយើងឃើញថា នាងជានារីដែលមានការអៀនខ្មាសស្ងៀមស្ងាត់ ក្នុងរឿងស្នេហានិងគោរពស្ដាប់បង្គាប់ម្ដាយណាស់ "... នាងជាយុវតីមួយ ដែលធ្លាប់ស្ដាប់បង្គាប់ម្ដាយជានិច្ចជានិរន្តន៍នាងមិនដែលហ៊ានតបវាចាឆ្លងឆ្លើយនិងម្ដាយនាងដោយរឹងត្អឹងឡើយ។ មួយវិញទៀតនាងមានខ្មាសច្រើន។ បើកាលណាឮគេនិយាយពីគូស្រករឡើង ខេមរកញ្ញាយើង ជាធម្មតាតែងតែនៅស្ងៀមមិនចរចាទោះត្រូវចិត្ត ឬមិនត្រូវចិត្តក៏ដោយ”។ តាមដំណើររឿងយើងឃើញថារហូតដល់ពេល នាងឈឺធ្ងន់ដោយវិបត្តិស្នេហានោះក៏នាងនៅតែមិននិយាយប្រាប់ម្ដាយពីការពិតក្នុងចិត្តនាងដែរ ។ តាមលោក នូ ហាច ការអៀនខ្មាសនេះវាទាក់ទងនឹងការលំអោនតាមប្រពៃណីគឺ ".... ប្រពៃណីមកសង្កត់អណ្ដាត នាងឲ្យស្ងៀមព្រោះយល់ឃើញថាតាំងពីបុរាណនាយមក ស្ត្រីខ្មែរមិនមានអំណាចរើសប្ដីលើខ្លួនឯងទេ”។ បានន័យថាលោកចង់រិះគន់តែប្រពៃណីតែប៉ុណ្ណោះ ឯកំហុសបុគ្គលលោកមិននិយាយឡើយ។

ក្នុងបញ្ហានេះយើងយល់ថា ការស្ងៀមស្ងាត់របស់វិធាវី គឺជាបុព្វហេតុផ្ទៃក្នុងនៃវិបត្តិរបស់នាង ព្រោះ ម្ដាយនាងដែលចេះតែបន្តកំហុសនោះ ក៏ព្រោះតែគាត់មិនយល់រួចដោយគ្មានអ្នកពន្យល់។ យើងជឿថាបើម្ដាយមានទម្លាប់មួយ គឺមិនសួរយោបល់ពីកូន ដូចយាយនួន រួចកូនមានទម្លាប់មួយ គឺមិនព្រមថាថ្លែងប្រាប់ម្ដាយពី ទស្សនៈយោបល់ ពីទុក្ខកង្វល់របស់ខ្លួនដូចវិធាវីនោះ វាគ្មានពេលណាដែលម្ដាយ និងកូនអាចយល់គ្នាបានឡើយរួចហើយ

សោកនាដកម្មនោះ វាចៀសមិនរួចឡើយ។ ដូចនេះយើងអាចថាសោកនាដកម្ម "ផ្កាស្រពោន" វាផ្ដើមចេញពីការមិនយល់គ្នារវាងម្ដាយកូនដោយរបាំងប្រពៃណី និងការនិយមទ្រព្យសម្បត្តិ។

ម្យ៉ាងទៀត អ្នកនិពន្ធបានបង្ហាញឲ្យយើងឃើញដែរថា វិធាវីជានារីដែលមានមនោសញ្ចេតនាជ្រាលជ្រៅណាស់ ជានារីដែល មានលក្ខណៈអណ្ដែតអណ្ដូង ជាអ្នកដែលងាយធ្លាក់ក្នុងទុក្ខកង្វល់ រួចមិនងាយរើខ្លួនរួចឡើយ។ នាងរៀនសូត្របានតិចតួចមែន តែនាងចូលចិត្តអានប្រលោមលោកពិសេសបណ្ដារឿងបែបមនោសញ្ចេតនា។ ដោយនាងជានារីមានប្រាជ្ញា ការរក្សាខ្លួននៅតែក្នុងផ្ទះតាមលក្ខណៈខ្មែរ ធ្វើឲ្យនាងចូលចិត្តស្រមៃតាមដំណើររឿងប្រលោមទាំងនោះ ។ ឥទ្ធិពលនៃប្រលោមលោកមួយចំនួនដូចជា "ប៉ូលនិងវិហ្សិនី" បានធ្វើឲ្យនាងគិតដល់តែប៊ុនធឿន ម្នាក់ប៉ុណ្ណោះ។ ដូចនេះហើយទើបនាងមិនអាចផ្លាស់ប្ដូរចិត្តពីប៊ុន ធឿនបានភ្លាមៗរួចការគិតខ្វាយខ្វល់យ៉ាងខ្លាំង ធ្វើឲ្យនាងធ្លាក់ខ្លួនឈឺ ឯសភាពទន់ខ្សោយខាងផ្លូវចិត្តរបស់នាងធ្វើឲ្យនាងយល់ព្រមទទួលស្ថានភាពបែបនោះដោយមិនរើបំរះ នាងព្រមឈឺ ព្រមព្រួយ រួចព្រមស្លាប់ ដោយមិនធ្វើអ្វីសូម្បីបន្តិចប្រឆាំងនឹងស្ថានភាពនោះ...។ វិធាវីនៅតែស្ងួកស្ងឹង តែនាងនៅវិញ្ញាណចាំនៅជានិច្ច...ណ្ហើយ ធ្វើម្ដេចកម្មក្រាស់របស់ខ្លួន..."។ ក្នុងន័យនេះយើងយល់ថាបើវិធាវីមានមនោខ្លាំងក្លាមិនព្រម បណ្ដោយតាមវាសនានោះ ស្ថានការណ៍នឹងប្រែប្រួលរួចប្រហែលជាគ្មានសោកនាដកម្មនោះឡើយ។ ដូចនេះកត្តាចិត្តសាស្ត្រផ្ទាល់របស់បុគ្គលគឺលក្ខណៈអណ្ដែតអណ្ដូងរបស់វិធាវីក៏ជាដើមហេតុនៃសោកនាដកម្ម "ផ្កាស្រពោន" ដែរ។

សរុបមកគ្រប់ការបង្ហាញរបស់អ្នកនិពន្ធ ទាំងបុគ្គលភាពតួអង្គ ទាំងទំនាក់ទំនងក្នុងគ្រួសារ និងទាំងលក្ខខ័ណ្ឌសង្គម សុទ្ធសឹងជាហេតុផលនៃសោកនាដកម្មស្នេហាទាំងអស់។ ពោលគឺនាងវិធាវី មិនមែនស្លាប់តាមគំនិតអ្នកនិពន្ធទេ រួចលោក នូ ហាច ក៏ពុំដោះស្រាយតាមអត្តនោម័តរបស់ខ្លួនដើម្បីជួយវិធាវីដែរ ដូចនេះសោកនាដកម្មនោះ ពិតជាបានកើតមានឡើងក្នុងតថភាពសង្គមបែបនោះ គឺជាសោកនាដកម្មដែលមានលក្ខណៈសង្គម និងដែលបង្កើតតម្លៃតថៈដល់ស្នាដៃពិតប្រាកដ។

### ៣-ឥទ្ធិពលមរណភាពវិធាវី:

រឿងផ្កាស្រពោន បានបញ្ចប់ដោយបង្ហាញពីភាពក្រៀមក្រំនៃតួអង្គសំខាន់ៗ ដោយសារតែមរណភាពរបស់នាងវិធាវី។ អ្នកនិពន្ធបានបញ្ជាក់ថា ដោយសេចក្ដីទុក្ខព្រួយនេះឃាយនួន..." មានស្បែកមុខទ្រុឌទ្រោមថ្ពាល់ខូងភ្នែករូងនិងមានទឹកភ្នែកហូរ ហោម..." [៩]។ ឯ ប៊ុនធឿន " ក៏បានអុជចង្កៀងមើលសំបុត្រដែលនាងវិធាវីសរសេរទុកឲ្យមុនពេលស្លាប់ ដោយមានទឹកភ្នែកហូរស្រក់មិនដាច់ដែរ " [១០]។ យើងយល់ថា ចំពោះអ្នកដែលបានអានស្នាដៃនេះក៏អាចទទួលអារម្មណ៍មិនរីករាយចំពោះមរណភាពនោះដែរ។ សោកនាដកម្មដែលអ្នកនិពន្ធ បានបង្កើតនៅទីបញ្ចប់នោះ គឺបានធ្វើឲ្យយើងចាប់អារម្មណ៍ទៅដល់កំហុសឆ្គងទាំងក្នុងជីវទស្សនៈ ទាំងក្នុងជីវភាពសង្គម ដូចជាការនិយមទ្រព្យសម្បត្តិ ការរៀបចំទុកដាក់កូនចៅតាមទំនើងចិត្តម្ដាយ ការងប់ងល់ក្នុងអបិយជំនឿ និងការអនុវត្តសីលធម៌តឹងរ៉ឹងពេកចំពោះនារី(កូនស្រី)។ និយាយរួម ការបង្ហាញពីមរណភាពវិធាវី អាចចាត់ទុកថា ជាការបង្ហាញពីវិបាកដ៏ធំ នៃកំហុសឆ្គងទាំងនោះ ឬក៏អាចជាមេរៀនសម្រាប់ប្រជាជនខ្មែរក្នុងការអនុវត្តប្រពៃណី ឬរបៀបរបបរស់នៅឲ្យបានថយគុណវិបត្តិ។

---

[៩] នូ ហាច រឿងផ្កាស្រពោន ទំព័រ៧៤ បោះពុម្ពផ្សាយឡើងវិញតាមច្បាប់ដើម ដោយក្រសួងអប់រំយុវជន និងកីឡា២០០១

[១០] -ដ- ទំព័រ៩០

• ចំពោះមាតាខ្មែរ ទីមួយគាត់អាចមើលឃើញថាការទុកដាក់កូនចៅត្រូវមានកូនចៅចូលរួមព្រោះម្តាយអាចបង្កើតបានតែរូបរាងកូនតែប៉ុណ្ណោះឯមនោសញ្ចេតនាស្នេហានោះ គាត់មិនអាចបង្កើត ឬផ្លាស់ប្តូរ តាមចិត្តគាត់បានឡើយ។ ទីពីរគាត់អាចយល់ថាទ្រព្យសម្បត្តិ មិនអាចផ្តល់សុភមង្គលដល់មនុស្សបានឡើយ បើកាលណាគេមានទុក្ខព្រួយដោយប្រការអ្វីមួយ ព្រោះទ្រព្យសម្បត្តិ វាអាចផ្តល់ដល់មនុស្សបានតែផាសុកភាព នៃរាងកាយតែប៉ុណ្ណោះ ឯសុភមង្គលរបស់មនុស្ស វាអាចកើតមានបាន លុះណាតែគេមានសេចក្តីសុខទាំងកាយទាំងចិត្ត។ ក្នុងបញ្ហានេះកន្លងមកយើងឃើញថា មាតាបិតាគាត់មានជំនឿខ្លាំងណាស់លើទស្សនៈ និងទង្វើរបស់គាត់ពាក្យសម្តីយាយនួន ក្នុងរឿងផ្កាស្រពោន អាចជាអំណះអំណាងក្នុងរឿងនោះ "...ចូរនាងរក្សាចិត្តនាងឲ្យហ្នឹងហ្នបំភ្លេចចៅ ប៊ុន ធឿន ចោលទៅ។ ដល់ថ្ងៃក្រោយទៅលុះនាងបានប្រកបដោយតែសុវត្ថិភាព និងសុភមង្គលនាងនឹងនឹកឃើញថាម៉ែគាត់និយាយត្រូវមែន"។ អ្វីដែលជាការធានាដល់សុភមង្គល តាមគំនិតគាត់នោះវាគ្មានអ្វីក្រៅពីទ្រព្យសម្បត្តិឡើយ..."។ ក្នុងលោកនេះ បើគ្មានទ្រព្យសម្បត្តិហើយ សេចក្តី ទុកសោកនានាឥតមកបៀតបៀនបានឡើយ"។ តែការជឿជាក់នោះអាចនឹងថយទៅវិញតាមរយៈការសារភាពរបស់យាយនួន ក្រោយមរណភាពវិធាវី "...មីងបានជាខុសទៅហើយ...មីងមិនបាននឹកស្មានសោះថា សេចក្តីស្នេហាមានកម្លាំងអ្វីម្លេះ"។ រួចការបង្ហាញពីទុក្ខសោកយ៉ាងខ្លាំងរបស់យាយនួន ក៏អាចឲ្យគាត់ឃើញថាជីវិតមនុស្ស ពិសេសកូនចៅវា មានតម្លៃលើសទ្រព្យសម្បត្តិ ដែលជាកត្តាកំណត់ សុភមង្គលក្នុងគ្រួសារ។ មាតាបិតានឹងឃើញថា ចំពោះអ្នកបាត់បង់កូនស្រីជាទីស្រឡាញ់ដូចយាយនួននោះទោះបីគាត់មានទ្រព្យសម្បត្តិច្រើនយ៉ាងណាក៏គាត់គ្មានសុភមង្គលដែរ។

• ឯចំពោះនារីខ្មែរ គេនឹងឃើញថា ការខ្មាសអៀនមិនហ៊ាននិយាយស្តីពីវិបត្តិផ្លូវចិត្តរបស់ខ្លួនប្រាប់ មាតាបិតា នោះមិនអាចចាត់ទុកថាជាសីលធម៌ដ៏ប្រពៃសម្រាប់នាងឡើយ ព្រោះគេឃើញយ៉ាងច្បាស់លាស់តាមដំណើររឿង គឺថាយាយនួនដែលចេះតែបន្តធ្វើតាមគំនិតគាត់នោះ ក៏ដោយសារនាងវិធាវី មិនព្រមកនិយាយអ្វីទាំងអស់។ ដូចនេះក្រោយមរណភាពវិធាវី គេនឹងឃើញថាខ្លួននាងផ្ទាល់ក៏មានកំហុសដែរ គឺខុសដោយការអនុវត្តត្រឹមត្រូវពេកតាមគោលការណ៍សីលធម៌សង្គមខ្មែរចំពោះនារី។ ជាទូទៅយើងឃើញថា ខ្មែរបានបង្កើតច្បាប់ទូន្មាន មួយដែលគេយល់ថា ជាសីលធម៌ល្អណាស់ចំពោះនារី ការបង្ហាញបុគ្គលិកលក្ខណៈវិធាវី របស់លោក នូ ហាច ជាភស្តុតាងជាក់ស្តែងចំពោះប្រការនេះ។ តែទីបញ្ចប់ពេលវិធាវីស្លាប់ទើបគេឃើញថា ច្បាប់ចរិយាសាស្ត្របែបនោះ វាគ្មានអ្វីក្រៅពីរបាំងរាំងស្ទះជំហាននារីខ្មែរ មិនឲ្យស្គាល់តម្លៃនៃសិទ្ធិមនុស្សនិងអារ្យធម៌ពិភពលោកឡើយ។

សរុបមកយើងឃើញថា មរណភាពវិធាវី បានកែប្រែយ៉ាងសំខាន់ដល់របៀបរបបអនុវត្តប្រពៃណីនៃប្រជាជនយើង ដោយម្យ៉ាងវាបានបណ្តុះឲ្យមានស្មារតីមនុស្សធម៌ដល់មាតាបិតាខ្មែរ ដែលធ្លាប់តែគិតអំពីតម្លៃទ្រព្យសម្បត្តិនិងធ្លាប់តែនិយមបំបាត់សិទ្ធិកូនចៅក្នុងការជ្រើសរើសគូស្រកម្យ៉ាងទៀត វាបានបណ្តុះចរិតសកម្មម្ចាស់ការដល់នារីខ្មែរទាំងឡាយដែលធ្លាប់តែលុះតាមគន្លងទោះបីខុស ឬត្រូវក៏មិនហ៊ានស្តីឲ្យចូលរួមក្នុងការកែប្រែរបៀបរបបរស់នៅតាម បែបប្រពៃណីដូនតាយើងនោះឲ្យកាន់តែប្រពៃនិងមានតម្លៃសម្រាប់មនុស្សគ្រប់វ័យក្នុងសង្គមផង[១១]។

### ៤-ធម្មជាតិក្នុងរឿងផ្កាស្រពោន:

ក្នុងការតែងនិពន្ធ ទោះបីលោក នូ ហាច បានតាក់តែងស្នាដៃបែបទារុណកថា ក៏លោកពុំបាននាំយើងឲ្យមានទស្សនៈទុទិដ្ឋិនិយមទាំងស្រុងនោះដែរ។ ជាការពិតណាស់ដែលលោកបានលាតត្រដាងតថភាពមួយចំនួន

[១១] សោម សុមុនី "វិភាគទានក្នុងការសិក្សាអក្សរសិល្ប៍ខ្មែរ" ទំព័រ១៥៣ ឆ្នាំ២០១៥

ដើម្បីជាកម្មវត្ថុនៃការរិះគន់តែទន្ទឹមនឹងនោះលោកក៏បានបង្ហាញលក្ខណៈតថផ្សេងទៀតដែលអាចបង្កើតមនោសញ្ចេតនា ស្នេហាមាតុភូមិដល់អ្នកអានដែរ។ ការបង្ហាញជាពិសេស អំពីធម្មជាតិនៃមាតុភូមិកម្ពុជាពីសម្បត្តិវប្បធម៌ជាតិគឺជាកត្តាកំណត់ទស្សនៈសុទិដ្ឋិនិយមនោះ។

ក្នុងការតែងនិពន្ធ យើងសង្កេតឃើញ លោក នូ ហាច និយមបង្ហាញធម្មជាតិភ្ជាប់នឹងដំណើររឿងផង រួចភ្ជាប់នឹងមនោសញ្ចេតនាតួអង្គផង។ ដើម្បីភ្ជាប់ធម្មជាតិ និងដំណើររឿងនោះ គឺលោកបានធ្វើការពិពណ៌នាធម្មជាតិដែលមាននៅកន្លែងកើតរឿងនោះតែម្តង។ ជាទូទៅ ការពិពណ៌នាធម្មជាតិបែបនោះរបស់លោក វាមានលក្ខណៈសព្វគ្រប់គ្មានចន្លោះ ឯរចនាបថក៏មានសម្រស់អាចទាក់ទាញចិត្តអ្នកអានបាន។ ដូចជានៅដើមរឿងលោក បានពិពណ៌នាអំពីទេសភាពនៃវាលស្រែនារដូវវស្សា ដែលពួកសិស្សានុសិស្សទាំងឡាយមើលពីលើរថភ្លើងពេលពួកគេធ្វើដំណើរទៅស្រុកកំណើតសម្រាកវ៉ាកងធំ។ តាមរយៈការពិពណ៌នានោះ អ្នកអានអាចស្រមៃឃើញទាំងអស់ នូវទិដ្ឋភាពវាលស្រែជារួម ដែលមានទឹកសស្វាចពេញព្រៀបប្រកបដោយរលកពព្រាំ មកយោលយោគដើមស្រូវខ្ចីពណ៌បៃតងដែលលាយឡំដោយវារីជាតិទាំងឡាយ ដែលមានសម្រស់អស្ចារ្យ ដោយមានបុប្ផារីគ្រប់ពណ៌ ជាទីគាប់ចិត្តចេតនានៃបក្សីបក្សាគ្រប់ប្រភេទឲ្យចុះរកស៊ីព្រោងព្រាតទាំងហ្វូងៗ...។ ដោយអនុវត្តន៍ការពិពណ៌នារបៀបនោះជាច្រើនលើកលោក នូហាច បាននាំយើងឲ្យស្គាល់ ធម្មជាតិនិងទីកន្លែងល្អៗជាច្រើនទៀតដែលទាក់ទងនឹងដំណើររឿងរបស់លោកដូចជា៖

- ទេសភាពនៃដងស្ទឹងសង្កែ នាពេលរាត្រី ក្រោមរស្មីអគ្គិសនីដែលចោលរន្ទះពណ៌មាសទៅក្នុងទឹក ពណ៌ខ្មៅដែលហូតត្រកួញខ្នាញ់...។
- ទេសភាពក្រុងសៀមរាប ដែលជាក្រុងតូចមួយស្អាតញញឹមលម្អដោយថ្នល់ដែលមានរុក្ខជាតិចោលម្លប់ទៅលើត្រឈឹងត្រឈៃ និងដោយកូនស្ទឹងតូចមួយដែលមានទឹកថ្លាហ្វង់ហូរមកបង្វិលរហាត់ធ្វើឲ្យឮសម្លេងថ្ងូរយ៉ាងស្រងេះស្រងោច...។
- ពិសេសនាំយើងឲ្យស្គាល់ទេសភាព និងធម្មជាតិនៃមាគ៌ាទៅកាន់អង្គរ ជាកេរ្តិ៍ដំណែលដ៏ល្បីល្បាញ នៃបុព្វបុរសខ្មែរដែលតាមអ្នកនិពន្ធថាទោះជាឋានតុសិតក៏មិនស្មើទីនោះដែរព្រោះទាំងក្លិនបុប្ផាព្រៃ ទាំងសម្លេងរៃដែលយំនៅលើចុងស្រឡៅ ឬចុងឈើទាលខ្ពស់ត្រដែតកប់អាកាសនោះសុទ្ធសឹងជាឱសថទិព្វដែល អាចចូលមករំលាយសេចក្តីសោកសៅនៃមនុស្សទាំងពួងបាន។

ចំពោះការបង្ហាញធម្មជាតិតាមមនោសញ្ចេតនាតួអង្គលោកច្រើនតែបង្ហាញយ៉ាងខ្លី ពេលតួអង្គ ពិសេសវិធាវី មានទុក្ខព្រួយ ដោយរើសយកតែធម្មជាតិណាដែលស្របតាមស្ថានការណ៍រឿងនិងស្ថានភាពតួអង្គនោះ។ ដូចជាក្នុងវគ្គមួយពេលវិធាវីក្រៀមក្រំ លោកសរសេរថា "សែងព្រះអាទិត្យនៃវេលាល្ងាចចាំង លើស្លឹកល្មុតបណ្តាលឲ្យមានរស្មីភ្លឺប្រាលដូចកម្ទេចសុវណ្ណៈ... វិធាវីដែលមានកក្រុស្ងប់ស្ងួតនាងអង្គុយមើលធម្មជាតិ...."។ ពេលខ្លះទៀតលោកពិពណ៌នាពីធម្មជាតិក្រៀមក្រំនារាត្រីកាលរួចបញ្ជាក់ថា" នៅក្នុងសន្ធិយាស្ងាត់នេះនាងវិធាវីនៅកណ្តោចកណ្តែងឈឺអួលផ្សាតែម្នាក់ឯង...។ យើងសង្កេតឃើញថា ដើម្បី បញ្ជាក់ពីមនោសញ្ចេតនាទុក្ខព្រួយទាំងនោះលោកនិយមពិពណ៌នាពីធម្មជាតិនាពេលល្ងាចឬពេលរាត្រីកាល។ ដោយប្រការនេះហើយ ទើបការបង្ហាញធម្មជាតិក្នុង រឿងផ្កាស្រពោន បានជួយឲ្យដំណើររឿងរឹតតែមានសភាពទន់ភ្លន់ ពីរោះនិងកាន់តែកំសត់ឡើងព្រោះជាទូទៅ រាត្រីកាលនៅប្រទេសខ្មែរពិសេសរាត្រីដែលមានដួងច័ន្ទ វាមានឥទ្ធិពលខ្លាំងណាស់លើអ្នកដែលមានមនោសញ្ចេតនាទន់ភ្លន់ដូចជាកវី។ យើងអាចថា លោក នូ ហាច បានប្រើប្រាស់ធម្មជាតិទាំងនោះចុចទម្លុះចំបេះដូងអ្នកមាន ដែលចូលចិត្តរឿងមនោសញ្ចេតនា។

សរុបមកការបង្ហាញធម្មជាតិក្នុងរឿងផ្កាស្រពោនម្យ៉ាងវាបណ្តុះមនោសញ្ចេតនាស្នេហាធម្មជាតិ ដល់អ្នកអាន រួចម្យ៉ាងទៀតវាជួយឲ្យស្នាដៃកាន់តែមានសម្រស់ និងកាន់តែមានតម្លៃកំសត់កាន់តែខ្លាំងឡើង។

**៥-ជីវភាពក្នុងរឿងផ្កាស្រពោន:**

ក្រៅពីការបង្ហាញធម្មជាតិ លោកនូ ហាច បាននាំយើងឲ្យស្គាល់ពីរបៀបរបបរស់នៅរបស់ប្រជាជន នៅបាត់ដំបង នៅស្រុកកំពង់ព្រះ។តាមការពិពណ៌នារបស់អ្នកនិពន្ធ យើងឃើញថា ប្រជាជន់ទូទៅ ជាជនជាតិខ្មែរប្រកបមុខរបរធ្វើស្រែ ឯចិនឬកូនចៅចិន ច្រើនធ្វើជំនួញគឺទិញស្រូវពីប្រជាជនយកទៅលក់បន្ត។ ឧទាហរណ៍ គ្រួសារប៊ុន ធឿនជាអ្នកជំនួញស្រូវ តែក្រោយការខាតបង់ដ៏ធំមកក៏ត្រូវធ្វើស្រែដោយខ្លួនឯងដែរ។ ចំណែកវាលស្រែតាមការបង្ហាញរបស់អ្នកនិពន្ធបញ្ជាក់ថា បាត់ដំបងពិតជាតំបន់កសិកម្មដ៏សំខាន់របស់ ប្រទេសខ្មែរដែរ "វាលស្រែ! វាលស្រូវ! ពាសពេញតៗជាប់គ្នា ដល់ជើងព្រៃដែលគេមើលទៅឃើញសន្លឹម"។

ការបញ្ជាក់ ឈ្មោះ ភូមិស្រុក និងការពិពណ៌នាយ៉ាងក្បោះក្បាយអំពីទិដ្ឋភាពទូទៅនៃភូមិស្រុកទាំងនោះ ពីផ្ទះសម្បែង ពីរបៀបរបបរស់នៅពីរបរកសិ ធ្វើឲ្យអ្នកអានហាក់មានអារម្មណ៍ថា តួអង្គទាំងនោះបានរស់នៅនិងធ្លាប់មានរឿងរ៉ាវទាំងនោះកើតឡើងនៅទីនោះមែនគឺមិនមែនអ្នកនិពន្ធប្រឌិតទេ។ ឯការនិទានដ៏គួរឲ្យចាប់អារម្មណ៍ពីក្រុមតាសូ អ្នកបម្រើគ្រួសារ ប៊ុន ធឿន ដែលធ្វើដំណើរដោយរទេះ ទៅរកត្រីសាច់នៅព្រៃរនាម (វគ្គទី១១) មិនត្រឹមតែបាននាំយើងឲ្យស្គាល់ពីជីវភាពប្លែកៗនៃប្រជាជនទាំងនោះទេតែថែមទាំងជួយបង្វែរអារម្មណ៍យើងដែលកំពុងតានតឹងដោយស្ថានភាពវិបាវីនោះឲ្យបានធូរស្រាលមួយរយៈ។

សរុបមកការបង្ហាញពីជីវភាពក្នុងរឿងផ្កាស្រពោនវាបានជួយឲ្យស្នាដៃពោរពេញដោយតម្លៃតថៈ ព្រោះទីកន្លែង និងជីវភាពប្រជាជនបែបនោះវាមានពិតនៅក្នុងប្រទេសយើង។ រួចម្យ៉ាងទៀតវាជាវិធីសាស្ត្រ ដ៏សំខាន់មួយដែលអ្នកនិពន្ធបានប្រើប្រាស់ដើម្បីប្តូរបរិយាកាសរឿងនោះផង។

**សរុបមក:**

តាមការសិក្សាកន្លងមកយើងឃើញថា តាមរយៈដំណើរជីវិតអភ័ព្វរបស់នារីខ្មែរម្នាក់ លោកនូ ហាច បានបកស្រាយប្រាប់យើងពីលក្ខណៈជីវភាពពិតប្រាកដរបស់ប្រជាជនខ្មែរនាសម័យកាលដែលលោករស់នៅ។ ដំណោះស្រាយ ក្នុងរឿងរបស់លោកដែលកំណត់មរណភាពវិបាវី វាទាក់ទងទាំងស្រុង ដល់ការបង្ហាញពីចំណុចអសកម្មទាំងឡាយក្នុងជីវភាពសង្គមខ្មែរពិសេសជីវភាពខាងស្មារតី។ យើងយល់ថាលោក នូ ហាច ដោយផ្អែកលើការិះគន់តថភាពសង្គមនេះ លោកបានបង្កើតគំនិតមនុស្សធម៌មួយយ៉ាងទូលំទូលាយក្នុងស្នាដៃ ធ្វើឲ្យស្នាដៃនោះមិនត្រឹមតែមានលក្ខណៈតថៈ និងលក្ខណៈជាតិតែប៉ុណ្ណោះទេ តែថែមទាំងពោរពេញដោយគំនិតអប់រំទៀតផង។ ដូចនេះក្រៅពីប្រយោជន៍ក្នុងការឧទ្ទិសដល់ទឹកដីកំណើតរបស់លោក ដែលបានបាត់បង់ដោយប្រទេសជិតខាងដណ្តើមយកដូចក្នុងការបញ្ជាក់របស់លោកក្នុងអារម្មណ៍ថាស្នាដៃនេះ វាមានប្រយោជន៍ពិសេសមួយទៀត ដោយវាបានកែប្រែជីវទស្សនៈប្រជាជនខ្មែរ ឲ្យកាន់តែប្រសើរឡើងថែមទៀតផង។ ម្យ៉ាងទៀត ការរចនាពាក្យពេចន៍ ឃ្លាប្រយោគដ៏ពីរោះ និងការតាក់តែងដំណើររឿង ដែលគួរឲ្យជក់ចិត្តវាអាចជាមេរៀនមួយយ៉ាងសំខាន់ ដល់អ្នកនិពន្ធជំនាន់ក្រោយ។ តាមន័យនេះ យើងអាចនិយាយបានថាលោក នូ ហាច គឺជានិម្មិតករមួយរូបយ៉ាងសំខាន់ ក្នុងប្រវត្តិអក្សរសិល្ប៍ខ្មែរ ដោយបង្កើតបាននូវស្នាដៃមួយដែលអាចជាគម្រូ ទាំងគំនិតរឿង ទាំងរបៀបរៀបចំភាសា នៃស្នាដៃអក្សរសិល្ប៍ ឯរឿងផ្កាស្រពោន គឺជានិម្មិតកម្មដែលមានតម្លៃប្រចាំសម័យកាលអក្សរសិល្ប៍ ប្រចាំទសវត្សរ៍ឆ្នាំ១៩៤០ នាសតវត្សរ៍ទី២០។

**សន្និដ្ឋានរួមៈ**

ក្រោយពីបានធ្វើការសិក្សាទៅលើរឿងទាំងពីរខាងលើនេះ យើងអាចសន្និដ្ឋានបានថា រឿងទាំងពីរខាងលើនេះ ទោះបីជាស្ថិតក្នុងសម័យកាលខុសគ្នា អ្នកនិពន្ធផ្សេងគ្នា និងបរិយាកាសសង្គម ព្រមទាំងស្ថានមិនដូចគ្នាយ៉ាងណាក៏ដោយ ក៏អ្នកនិពន្ធបានបង្ហាញពីតថភាពសង្គមខ្មែរ មានលក្ខណៈប្រហាក់ប្រហាក់គ្នា ជាពិសេសគឺអ្នកនិពន្ធបានបង្កប់នូវតម្លៃអប់រំជ្រាលជ្រៅដល់អ្នកអាន អ្នកស្ដាប់ អ្នកសិក្សា ដើម្បីជាការបណ្ដុះនូវស្មារតីជាតិនិយម និងការអភិរក្ស និងលើកស្ទួយស្នាដៃអក្សរសាស្ត្រជាតិ អក្សរសិល្ប៍ខ្មែរ ឱ្យរឹតតែមានតម្លៃនិងមានភាពរីកចម្រើន តាមរយៈការស្គាល់ពីតម្លៃអក្សរសិល្ប៍ ដោយៈ

- រឿងទាំងពីរនេះ សុទ្ធតែបានឆ្លុះបញ្ចាំងពីជីវភាពរស់នៅពីតថភាពសង្គមខ្មែរពិតៗ
- ស្នាដៃទាំងមូលបង្ហាញឲ្យយើងឃើញពីអ្វីៗដែលមានពិត នៅក្នុងប្រទេសកម្ពុជា ដូចជា ឈ្មោះទីកន្លែង ធម្មជាតិ និងជីវភាពសង្គមនាសម័យនោះជាដើម។
- អប់រំយុវជនទាំងឡាយឱ្យចេះតស៊ូក្នុងជីវិត ព្យាយាមជម្រុញការសិក្សារៀនសូត្រ បង្កើនការអានការសរសេរ សិក្សាស្រាវជ្រាវឱ្យបានជ្រៅជ្រះ ជម្នះគ្រប់ការលំបាក
- ប្រជាជនខ្មែរជឿទៅលើទ្រឹស្ដីព្រះពុទ្ធសាសនា តាចឹមលើកពាក្យបណ្ដាំ " អត្តាហិអត្តនោនាថោ " (គឺខ្លួនទីពឹងខ្លួន) ចំពោះកូនប្រុសគាត់ ឱ្យចាំនឹកឃើញជានិច្ច។
- អ្នកនិពន្ធបង្កើតគំនិតផ្សះផ្សារវណ្ណៈ និងការឲ្យតម្លៃលើគុណធម៌ មនុស្សធម៌ មេត្តាធម៌ ចំពោះមនុស្សដូចគ្នា ស្ថិតក្នុងទ្រឹស្ដីព្រះពុទ្ធសាសនា ដែលបង្រៀនមនុស្សឱ្យដោះស្រាយបញ្ហាតាមសន្តិវិធី និងដែលតែងតែប្រៀនប្រដៅមនុស្ស ឲ្យជឿលើកុសលលើអំពើល្អ។
- គោរពសិទ្ធិមនុស្សជាសកល គោរពសិទ្ធិគ្នាទៅវិញ ទៅមក (សិទ្ធិរស់នៅ សិទ្ធិបញ្ចេញយោបល់ សិទ្ធិទទួលបានការសិក្សាអប់រំ សិទ្ធិការងារ សិទ្ធិក្នុងការជ្រើសគូស្រករ...)។
- តាមរយៈស្នាដៃរបស់អ្នកនិពន្ធទាំងពីរនេះ គឺលោកញ៉ុក ថែម ចង់បង្ហាញការផ្សះផ្សារវណ្ណៈក្នុងសង្គមដើម្បីកសាងសន្តិភាពពេញលេញមួយ រីឯអ្នកនិពន្ធ នូ ហាច ចង់បង្ហាញកំហុសដ៏ធំមួយក្នុងសោកនាដកម្ម របស់នាងវិធាវី ដើម្បីពន្លេចចេញនូវ ភាពរឹងមាំរបស់យុវជនសម័យក្រោយៗ ការបណ្ដុះគំនិតជជែកពិភាក្សា សន្ទនានៅក្នុងគ្រួសារ និងសង្គមជាតិ ដើម្បីស្វែងរកដំណោះស្រាយមួយដែលអាចទទួលយកបាន ការលះបង់ចោលនូវជំនឿងប់ងល់គ្មានមូលដ្ឋានច្បាស់លាស់ ជាពិសេសគឺ អ្នកនិពន្ធបង្ហាញពីគុណតម្លៃខុសគ្នា នៃការអបរំ គុណធម៌ ភាពកតញ្ញូ ទ្រព្យសម្បត្តិ និងប្រពៃណីទំនៀមខ្មែរ៕

ធ្វើនៅសៀមរាបថ្ងៃសៅរ៍ ៥កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ពស.២៥៦២

ត្រូវនឹងថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៩

គ្រូបង្រៀន នៅវិទ្យាល័យ១០មករា១៩៧៩

ជា សារី

០៧៧ ៨៨៨ ៥២០ , ០១២ ៦៧១ ០៩៦

## ឯកសារយោង

- ញ៉ុក ថែំ រឿងកុលាបប៉ៃលិន  បោះពុម្ពផ្សាយឡើងវិញតាមច្បាប់ដើម ដោយក្រសួងអប់រំយុវជន និងកីឡា២០០១
- នូ ហាច រឿង ផ្កាស្រពោន  បោះពុម្ពផ្សាយឡើងវិញតាមច្បាប់ដើម ដោយក្រសួងអប់រំយុវជន និងកីឡា២០០១
- តាន់ សុគន្ធា និក្ខេបបទថ្នាក់បណ្ឌិត "ចលនាប្រលោមលោកខ្មែរសម័យទំនើបពីឆ្នាំ១៩៣៨-១៩៧០ ឆ្នាំ២០១១
- សោម សុមុនី "វិភាគទានក្នុងការសិក្សាអក្សរសិល្ប៍ខ្មែរ"  ឆ្នាំ២០១៥
- រ៉ាន់ឌី កាអុន ប្រាកដនិយម និងអណ្តែតអណ្តូងនិយម បោះពុម្ពនៅគ្រឹះស្ថានមិត្តភាព ភ្នំពេញ  ឆ្នាំ១៩៧៣
- អក្សរសាស្រ្តខ្មែរ ថ្នាក់ទី១២ ក្រសួងអប់រំ យុវជននិងកីឡា បោះពុម្ពផ្សាយ២០១១
- សម្តេចព្រះសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ ភាគទី១ ភាគទី២ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត ១៩៦៨

## ឯកសារជាបរទេស

- WWW.google.com/Realism in Literature

## ឯកសារតាមគេហទំព័រ

- https://km.wikipedia.org/wiki/ញ៉ុក_ថែម
- https://km.wikipedia.org/wiki/នូ_ហាច